១៦.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ភូមិកែប

ឈ្មោះសហគមន៍នេសាទ : ភូមិកែប
ភូមិ : កែប
សង្កាត់ : កែប
ក្រុង : កែប
ខេត្ត : កែប

# កិច្ចព្រមព្រៀង
# កន្លែងនេសាទសហគមន៍

## រវាង

នាយខណ្ឌរដ្ឋបាលជលផលកំពត ជាតំណាងស្របច្បាប់នៃរដ្ឋបាលជលផល មានអាសយដ្ឋាននៅភូមិទ្វី សង្កាត់អណ្តូងខ្មែរ ស្រុកកំពង់បាយ ខេត្តកំពត ទូរស័ព្ទលេខ ០១២ ៩៣២ ៩០៩ ហៅថា " ភាគី ក " ។

## និង

ប្រធានគណៈកម្មការសហគមន៍នេសាទភូមិកែប ជាតំណាងស្របច្បាប់ឲ្យសហគមន៍នេសាទ ដែលមានអាសយដ្ឋានស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប ទូរស័ព្ទលេខ ០៨៩ ៤៩០ ៦៩៦ ហៅថា " ភាគី ខ " ។

ភាគីទាំងពីរបានឯកភាពគ្នាចុះកិច្ចព្រមព្រៀងតាមលក្ខខណ្ឌដូចខាងក្រោម ៖

**ប្រការ ១.–**

ភាគី ក ប្រគល់ដែននេសាទដែលជាទ្រព្យសម្បត្តិរបស់រដ្ឋឲ្យភាគី ខ ធ្វើការគ្រប់គ្រង ការពារ អភិរក្ស អភិវឌ្ឍន៍ និងប្រើប្រាស់ធនធានជលផលរយៈពេល ៣ឆ្នាំ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ដោយធានានូវចីរភាពតាមរយៈការរៀបចំសហគមន៍នេសាទ ។

**ប្រការ ២.–**

ដែននេសាទនេះមានឈ្មោះថា " កន្លែងនេសាទសហគមន៍ភូមិកែប " ដែលលាតសន្ធឹងនៅក្នុង :

- ភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប ។

មាននិយាមកាដូចខាងក្រោម :

| ល.រ | X | Y |
|---|---|---|
| ១ | X= 426200 | Y= 1158624 |
| ២ | X= 426434 | Y= 1157649 |
| ៣ | X= 428721 | Y= 1158927 |
| ៤ | X= 428445 | Y= 1159882 |
| ៥ | X= 428396 | Y= 1160059 |
| ៦ | X= 428011 | Y= 1160078 |
| ៧ | X= 427981 | Y= 1159761 |
| ៨ | X= 427735 | Y= 1159581 |
| ៩ | X= 426989 | Y= 1159226 |

| | | |
|---|---|---|
| ១០ | X= 426900 | Y= 1159349 |
| ១១ | X= 426756 | Y= 1159207 |
| ១២ | X= 426678 | Y= 1159080 |
| ១៣ | X= 426597 | Y= 1158989 |

ដូចផែនទីដែលបានភ្ជាប់មកជាមួយ ។

**ប្រការ៣.–**

ភាគី ក ត្រូវបំពេញភារកិច្ចជាអ្នកសម្របសម្រួល ផ្តល់បច្ចេកទេស ទប់ស្កាត់បទល្មើស តាមដាន និងត្រួតពិនិត្យលើការរៀបចំ និងការប្រព្រឹត្តទៅរបស់សហគមន៍នេសាទដូចមានចែងនៅក្នុងមាត្រា ២៣ នៃអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្តីពី ការគ្រប់គ្រងសហគមន៍នេសាទ ។

**ប្រការ៤.–**

ភាគី ខ ត្រូវរៀបចំ ៖

- កន្លែងអភិរក្សព្រៃលិចទឹក ឬព្រៃកោងកាង
- កន្លែងអភិរក្សផ្កាថ្ម ឬស្មៅសមុទ្រ
- ស្រះ អាង អន្លង់ត្រីមេពូជ
- ស្ពានប្រឡាយ ព្រែក បឹង ស្រះ
- ដាំព្រៃលិចទឹក/កោងកាង
- ធ្វើវារីវប្បកម្ម
- បញ្ជូនសមាជិកសហគមន៍ ដើម្បីរៀនសូត្រនូវបច្ចេកទេសផលិតពូជត្រី
- ការងារអភិវឌ្ឍន៍ផ្សេងៗទៀត ។

**ប្រការ៥.–**

ភាគី ខ ត្រូវរៀបចំប្រជុំពិភាក្សាអំពី ទំហំ ចំនួន ប្រវែង និងប្រភេទឧបករណ៍នេសាទ ដែលអនុញ្ញាតឲ្យប្រើប្រាស់នៅក្នុងកន្លែងនេសាទសហគមន៍ ឲ្យសមស្របតាមស្ថានភាពភូមិសាស្ត្រ និងពេលវេលា ផ្អែកតាមច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធ ។

**ប្រការ៦.–**

ភាគី ខ មានភារកិច្ចថែរក្សាការពារធនធានធម្មជាតិដូចខាងក្រោម ៖

- ការពារព្រៃលិចទឹក (ព្រៃកោងកាង) ដែលមានស្រាប់ឲ្យបានគង់វង្ស ចាត់វិធានការទប់ស្កាត់ និងបង្ការភ្លើងឆេះព្រៃ
- រក្សា និងការពារដីទំនាបលិចទឹក សម្រាប់ដាំព្រៃលិចទឹក (កោងកាង)ឡើងវិញ

- លែងទៅក្នុងធម្មជាតិវិញនូវវារីសត្វ ដែលកំពុងរងគ្រោះថ្នាក់ជិតផុតពូជ នៅពេលដែលធ្វើនេសាទបាន
- ការពារសត្វព្រៃគ្រប់ប្រភេទនៅក្នុងដែននេសាទ ឬព្រៃលិចទឹក (កោងកាង) ។

**ប្រការ៧.–**

ភាគី ខ មិនត្រូវធ្វើសកម្មភាពដែលបង្កឲ្យខូចដែននេសាទ ឬគ្រោះថ្នាក់ដល់ធនធានជលផលដូចខាងក្រោម៖

- ចាប់នូវធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ ដូចមានចែងក្នុងប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចជាផ្សោតជាដើម
- លើកទំនប់ លុប ឬពីក បឹង ព្រែក ប្រឡាយ រណ្តៅ បៀរ ស្រះ ដែលពុំមានការអនុញ្ញាតពីស្ថាប័នជំនាញ
- កាប់ ឆ្ការ គាស់ រាន ឈូសឆាយព្រៃលិចទឹក ឬព្រៃកោងកាងក្នុងគោលបំណងហ៊ុំព័ទ្ធយកដីជាកម្មសិទ្ធ ឬវាតដីធ្វើស្រែចំការ ស្រែអំបិល ឬគោលបំណងផ្សេងៗឡើយ
- ធ្វើនេសាទ កាប់ព្រៃ ឬអុសក្នុងកន្លែងអភិរក្សជលផល ក្នុងកន្លែងនេសាទសហគមន៍
- ប្រើប្រាស់ឧបករណ៍ហាមឃាត់ ជាពិសេសឧបករណ៍នេសាទឆក់ត្រី និងឧបករណ៍នេសាទស្បៃមុង គ្រប់ប្រភេទ
- ប្រើប្រាស់ឧបករណ៍នេសាទខុសពីការកំណត់នៅក្នុងតារាងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ
- ចិញ្ចឹមត្រី ឬដាំសារាយ ដែលជាពូជនាំឲ្យខូចដល់បរិស្ថានធម្មជាតិ បំផ្លិចបំផ្លាញដល់ធនធានជលផល ឬបង្កអន្តរាយដល់ដែននេសាទ
- ធ្វើនេសាទ ឬធ្វើអាជីវកម្មផ្សេងៗទៀតដែលប៉ះពាល់ ឬរំខានដល់ការលូតលាស់នៃស្មៅសមុទ្រ ឬផ្កាថ្ម
- ប្រមូលផល ទិញលក់ ដឹកជញ្ជូន និងធ្វើសន្និធិផ្កាថ្ម
- ផលិត ទិញ លក់ ដឹកជញ្ជូន រក្សាទុកឧបករណ៍ឆក់ ឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ ឈិបយន្ត និងអួនអូសទឹកសាប
- ធ្វើនេសាទដោយមង ឬអួនគ្រប់ប្រភេទដែលមានក្រឡាតូចជាង ១,៥សង្ទីម៉ែត្រ និងធំជាងដប់ប្រាំ (១៥) សង្ទីម៉ែត្រ ក្នុងដែននេសាទទឹកសាប ឬទឹកប្រៃ ។

**ប្រការ៨.–**

ភាគី ខ ត្រូវចាត់វិធានការថែរក្សាការពារកន្លែងនេសាទសហគមន៍ដោយបំផុស ជំរុញ និងលើកទឹកចិត្តដល់សមាជិកសហគមន៍នេសាទគ្រប់រូបឲ្យរាយការណ៍ទៅសមត្ថកិច្ចរដ្ឋបាលជលផលដែលនៅជិតបំផុត ដើម្បីសហការទប់ស្កាត់បទល្មើសជ លផល ។

**ប្រការ៩.–**

ភាគី ខ ត្រូវអនុវត្តនូវភារកិច្ចដូចខាងក្រោម៖

- ប្រតិបត្តិយ៉ាងមឹងម៉ាត់តាមលក្ខន្តិក: បទបញ្ញាផ្ទៃក្នុង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ធានាឲ្យសមាជិកទាំងអស់ក្នុងសហគមន៍មានសិទ្ធិស្មើគ្នាលើការប្រើប្រាស់ធនធានជលផល
- សហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរដែលពាក់ព័ន្ធ ។

**ប្រការ១០.–**

ប្រសិនបើភាគី ខ មិនអនុវត្តតាមប្រការទាំងឡាយនៃកិច្ចព្រមព្រៀងនេះ ធ្វើឲ្យអន្តរាយដល់ដែននេសាទ ឬធនធានជលផលត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។

**ប្រការ១១.–**

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ អាចបញ្ឈប់មុនពេលកំណត់ដោយផ្អែកលើលក្ខខណ្ឌណាមួយដូចមានចែងក្នុងមាត្រា ២៧ នៃអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០៧ ស្តីពី ការគ្រប់គ្រងសហគមន៍នេសាទ ។

ក្នុងករណីដែលសហគមន៍នេសាទយល់ថា ការបញ្ឈប់កិច្ចព្រមព្រៀងពុំមានលក្ខណៈសមស្រប សហគមន៍ទអាចធ្វើការតវ៉ាមកប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល ។

**ប្រការ១២.–**

កិច្ចព្រមព្រៀងនេះអាចធ្វើការកែប្រែបានតាមការឯកភាពរបស់ភាគីទាំង ២ ស្របតាមច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងសហគមន៍នេសាទ ។

កិច្ចព្រមព្រៀងនេះ ត្រូវតម្កល់ទុកនៅស្នាក់ការសហគមន៍នេសាទ សាលាឃុំ សង្កាត់ ខណ្ឌរដ្ឋបាលជលផល សាលាខេត្ត ក្រុង រដ្ឋបាលជលផលថ្នាក់កណ្តាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយអាចចម្លងជូនភាគីពាក់ព័ន្ធ ដោយច្បាប់ចម្លងត្រូវមានប្រថាប់ត្រា។

ថ្ងៃទី.....៩..... ខែ.......[illegible].........ឆ្នាំ២០១១

ភាគី ក

**ប្រធានគណៈកម្មការសហគមន៍នេសាទភូមិកែប**

ហត្ថលេខា

ភាគី ខ

**នាយខណ្ឌរដ្ឋបាលជលផលកំពត**

ហត្ថលេខា

ស_ស៊ូរិន

**សាក្សី**

**ចៅសង្កាត់**

មេឃុំ

[illegible]

# ផែនទីកន្លែងនេសាទសហគមន៍កែប

## សង្កាត់កែប ក្រុងកែប ខេត្តកែប

### ផ្ទៃសហគមន៍នេសាទទំហំ ២៧០ ហិកតា




| Point | X | Y |
|---|---|---|
| 1 | 426189 | 1168632 |
| 2 | 428810 | 1169063 |
| 3 | 428424 | 1169992 |
| 4 | 428720 | 1168929 |
| 5 | 426433 | 1167653 |

0 2 4 Km

## សញ្ញាផែនទី

ព្រំប្រទល់ស្រុក
ព្រំប្រទល់ឃុំ
សាលាខេត្ត និង សាលាក្រុង
សាលាស្រុក និង សាលាឃុំ
ក) សាលារៀន ខ) វត្ត
ដីវាល
ព្រំប្រទល់សហគមន៍នេសាទ......
ទិក្រា
ភូមិ
ផ្លូវ
ព្រៃអំពិល
ចម្ការ ស្វាយ ដូង ឬ ព្រៃកាង
ក) ទឹកខ្ពប ខ) ទឹកមិនខ្ពប
ក) ផ្លូវជាតិ ខ) ផ្លូវក្រោកជាតិ
ក) វាលស្រែ ខ) វាលស្រែលិចទឹក
ក) ទឹកភ្នំ ខ) ដីលេចក្នុងភូមិ
ភ្នំ.........................
ផ្លូវ.........................

COORDINATION SYSTEM

| | |
|---|---|
| Projection | UTM |
| Zone | 48 R |
| Horizontal Datum | Indian 1960 |
| Spheroid | Everest |
| Unit | Meter |
| Prepared by | CFDD FiA 2012 |
| Scale | 1:50 000 |

លេខ: ៥៤៤ ៣.ក
បានឃើញ និងបញ្ជូនមក
លោកអភិបាលនៃគណៈអភិបាលក្រុងកែប
"ដើម្បីពិនិត្យ និងសម្រួល"
ថ្ងៃទី 08 ខែ 08 ឆ្នាំ២០១២
ចៅសង្កាត់កែប

បានឃើញ និងបញ្ជូនមក
លោកចៅសង្កាត់កែប
"ដើម្បីពិនិត្យ និងសម្រួល"
ថ្ងៃទី 08 ខែ 08 ឆ្នាំ២០១២
មេភូមិកែប

ថ្ងៃទី ៤ ខែ ៤ ឆ្នាំ២០១២
ប្រធានគណៈកម្មការសហគមន៍នេសាទកែប

លេខ: ៣៦៤ ខ.ក
បានឃើញ និងបញ្ជូនមក
ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកែប
"ដើម្បីពិនិត្យ និងសម្រួល"
ក្រុងកែប ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២
អភិបាលនៃគណៈអភិបាលក្រុងកែប

លេខ: ២២១ ខ.ក
បានឃើញ និងគោរពជូន
លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកែប
"ដើម្បីពិនិត្យ និងសម្រួល"
កែប ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១២
ប្រធានខណ្ឌរដ្ឋបាលជលផលកំពត

លេខ: ១៣៦ ខ.ក
បានឃើញ និងគោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលកំពត
"ដើម្បីពិនិត្យ និងសម្រួល"
ក្រុងកែប ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១២
អភិបាលនៃគណៈអភិបាលក្រុងកែប

លេខ: ១០១៤ ស.ជ.ខ.ក
បានឃើញ និងឯកភាព
ថ្ងៃទី ១៤ ខែ ... ឆ្នាំ ២០១២
អភិបាលនៃគណៈអភិបាលខេត្តកែប

លេខ: ២៣៦៣ ក.ស.ក
បានឃើញ និងគោរពជូន
ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
"ដើម្បីពិនិត្យ និងសម្រេច"
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១២
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
អគ្គនាយករដ្ឋបាលជលផល

...កសក
បានឃើញ និងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០១២
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទភូមិកែប សង្កាត់កែប
# ក្រុងកែប ខេត្តកែប

| ល-រ | នាម-គោត្តនាម | ភេទ | អាយុ | តួនាទី | ភូមិ | ថ្ងៃ ខែ ចូលជាសមាជិក |
|---|---|---|---|---|---|---|
| ១ | ចក់ នី | ប | ៥៨ | នេសាទ | កែប | ១០/០៨/២០១១ |
| ២ | អ៊ុយ ទ្រី | ប | ៤៦ | នេសាទ | កែប | ១០/០៨/២០១១ |
| ៣ | កែវ សារឿន | ប | ៤៧ | នេសាទ | កែប | ១០/០៨/២០១១ |
| ៤ | វួច ឆេង | ស | ៣៥ | នេសាទ | កែប | ១០/០៨/២០១១ |
| ៥ | លាង ផៃ | ស | ៣០ | នេសាទ | កែប | ១០/០៨/២០១១ |
| ៦ | ចាប ប៊ុនខ្លី | ប | ៣៦ | នេសាទ | កែប | ១០/០៨/២០១១ |
| ៧ | ប៉ែន ញឹក | ប | ៥២ | នេសាទ | កែប | ១០/០៨/២០១១ |
| ៨ | គុង វណ្ណស៊ី | ប | ៤៣ | នេសាទ | កែប | ១០/០៨/២០១១ |
| ៩ | សេង គុយ | ប | ២២ | នេសាទ | កែប | ១០/០៨/២០១១ |
| ១០ | ឡុង សុវណ្ណរា | ប | ៣៧ | នេសាទ | កែប | ១០/០៨/២០១១ |
| ១១ | កែត ចូក | ប | ៤០ | នេសាទ | កែប | ១៥/០៨/២០១១ |
| ១២ | ហៃ ភា | ប | ៤៩ | នេសាទ | កែប | ១៥/០៨/២០១១ |
| ១៣ | ព្រំ ភន | ប | ៥០ | នេសាទ | កែប | ១៥/០៨/២០១១ |
| ១៤ | ចក់ ឆុន | ប | ៤០ | នេសាទ | កែប | ១៥/០៨/២០១១ |
| ១៥ | នាក់ ឃាម | ប | ៤៧ | នេសាទ | កែប | ១៥/០៨/២០១១ |
| ១៦ | ហៃ ស៊ុន | ប | ២៨ | នេសាទ | កែប | ១៥/០៨/២០១១ |
| ១៧ | ហៃ ថង | ប | ៤២ | នេសាទ | កែប | ១៥/០៨/២០១១ |

| | | | | | | |
|---|---|---|---|---|---|---|
| ១៨ | ទៅ កៅ | ប | ៥៣ | នេសាទ | កែប | ១៥/០៨/២០១១ |
| ១៩ | អំ ផន | ស | ៤៨ | នេសាទ | កែប | ១៥/០៨/២០១១ |
| ២០ | រិត ហុង | ប | ៤០ | នេសាទ | កែប | ២៧/០៨/២០១១ |
| ២១ | រិន ផាក់ | ប | ១៩ | នេសាទ | កែប | ២៧/០៨/២០១១ |
| ២២ | ចាប រី | ស | ៤៣ | នេសាទ | កែប | ២៧/០៨/២០១១ |
| ២៣ | ខាន់ វណ្ណៈ | ប | ៤៤ | កសិករ | កែប | ២៧/០៨/២០១១ |
| ២៤ | តាន់ ជេង | ប | ៨២ | កសិករ | កែប | ២៧/០៨/២០១១ |
| ២៥ | រ៉ិត ហេង | ប | ៤៥ | នេសាទ | កែប | ២៧/០៨/២០១១ |
| [illegible] | ទីម វ៉ាន់វ៉ាន់ | ប | ២៨ | នេសាទ | កែប | ២៧/០៨/២០១១ |
| [illegible] | សូ ណារិន | ប | ៣២ | នេសាទ | កែប | ២៧/០៨/២០១១ |
| ២៨ | ព្រំ សារី | ប | ៤០ | នេសាទ | កែប | ២៧/០៨/២០១១ |
| ២៩ | ទីម វ៉ាន់រី | ប | ២៣ | នេសាទ | កែប | ២៧/០៨/២០១១ |
| ៣០ | ទីម វ៉ាន់វ៉ាន់ | ប | ២២ | នេសាទ | កែប | ២៧/០៨/២០១១ |
| [illegible] | លឹម ហ | ប | ៤៦ | នេសាទ | កែប | ២៧/០៨/២០១១ |
| ៣២ | ឡុង ថេង | ប | ៥០ | នេសាទ | កែប | ២៧/០៨/២០១១ |
| ៣៣ | តេង ចិន | ប | ២៤ | នេសាទ | កែប | ២៧/០៨/២០១១ |
| ៣៤ | ចាប ញ៉ | ប | ៦១ | នេសាទ | កែប | ២៧/០៨/២០១១ |
| ៣៥ | អ៊ុយ ផុក | ប | ៣៧ | នេសាទ | កែប | ២៧/០៨/២០១១ |
| ៣៦ | សែស ម៉ន | ប | ២៤ | នេសាទ | កែប | ២៧/០៨/២០១១ |
| ៣៧ | សាឃឿ សាវ៉ន | ប | ៦៤ | នេសាទ | កែប | ២៧/០៨/២០១១ |
| ៣៨ | រុន អេង | ប | ៤៦ | នេសាទ | កែប | ២៧/០៨/២០១១ |
| ៣៩ | ចាប លីមេង | ស | ៤៣ | កសិករ | កែប | ២៧/០៨/២០១១ |
| ៤០ | ប្រាក់ សាមើត | ស | ៣៣ | កសិករ | កែប | ២៧/០៨/២០១១ |

| | | | | | | |
|---|---|---|---|---|---|---|
| ៤១ | ហុង សុគណន្ធា | ស | ៤៤ | កសិករ | កែប | ២៧/០៨/២០១១ |
| ៤២ | នាក់ យុំ | ស | ៥២ | កសិករ | កែប | ២៩/០៨/២០១១ |
| ៤៣ | អ៊ឹង សៅន្នី | ប | ៣៧ | ពេទ្យសត្វ | កែប | ២៩/០៨/២០១១ |
| ៤៤ | យ៉ឹង សេងថៃ | ប | ៣៧ | កសិករ | កែប | ២៩/០៨/២០១១ |
| ៤៥ | ហុង ប៊ុនលីម | ប | ៣៤ | កសិករ | កែប | ២៩/០៨/២០១១ |
| ៤៦ | អ៊ិត ចន្ថា | ស | ៣៦ | នេសាទ | កែប | ២៩/០៨/២០១១ |
| ៤៧ | កៅ នាម | ស | ៣៧ | នេសាទ | កែប | ២៩/០៨/២០១១ |
| ៤៨ | ចាប ផាត | ស | ៦២ | នេសាទ | កែប | ២៩/០៨/២០១១ |
| ៤៩ | ជួន ឡាន | ប | ៣៩ | នេសាទ | កែប | ២៩/០៨/២០១១ |
| ៥០ | លីម ចន្ថា | ប | ៣៨ | នេសាទ | កែប | ២៩/០៨/២០១១ |
| ៥១ | ង៉ែត តក់ | ប | ៤៥ | នេសាទ | កែប | ២៩/០៨/២០១១ |
| ៥២ | ព្រំ ចាន់ | ប | ៣៧ | នេសាទ | កែប | ២៩/០៨/២០១១ |
| ៥៣ | ជា សារឿន | ប | ៦០ | នេសាទ | កែប | ២៩/០៨/២០១១ |
| ៥៤ | អៀម ដួរ | ប | ៣៧ | នេសាទ | កែប | ២៩/០៨/២០១១ |
| ៥៥ | ខាន់ សាម៉ុន | ប | ៥៥ | នេសាទ | កែប | ២៩/០៨/២០១១ |
| ៥៦ | ណុប សេង | ប | ៣៦ | នេសាទ | កែប | ២៩/០៨/២០១១ |
| ៥៧ | ខៀវ ជាភ៊ត | ប | ៤៨ | នេសាទ | កែប | ២៩/០៨/២០១១ |
| ៥៨ | ទឹម ភ៊ន់វ៉ែម | ប | ២៥ | នេសាទ | កែប | ២៩/០៨/២០១១ |
| ៥៩ | ទូច សាវុធ | ប | ២៥ | នេសាទ | កែប | ២៩/០៨/២០១១ |
| ៦០ | ប៊ុយ រី | ប | ៣៨ | នេសាទ | កែប | ២៩/០៨/២០១១ |
| ៦១ | អ៊ុយ កៅហេង | ប | ៣៩ | នេសាទ | កែប | ២៩/០៨/២០១១ |
| ៦២ | ជាង អាំ | ប | ៣៥ | នេសាទ | កែប | ២៩/០៨/២០១១ |
| ៦៣ | ទឹម ម៉ន | ប | ២៧ | នេសាទ | កែប | ២៩/០៨/២០១១ |

| | | | | | | |
|---|---|---|---|---|---|---|
| ៦៤ | ណុប គា | ប | ៤៥ | នេសាទ | កែប | ២៩/០៨/២០១១ |
| ៦៥ | ឃឹម ចថុល | ស | ៤០ | នេសាទ | កែប | ២៩/០៨/២០១១ |
| ៦៦ | ជុន ឆក | ប | ៤៧ | នេសាទ | កែប | ២៩/០៨/២០១១ |
| ៦៧ | ណុប មករា | ប | ២៨ | កសិករ | កែប | ២៩/០៨/២០១១ |
| ៦៨ | ចាប វុធន្នី | ប | ៣៥ | នេសាទ | កែប | ២៩/០៨/២០១១ |
| ៦៩ | ហុំ សេន | ស | ៥៩ | នេសាទ | កែប | ១៥/០៩/២០១១ |
| ៧០ | រិន ស៊ីណា | ស | ២៦ | នេសាទ | កែប | ១៥/០៩/២០១១ |
| ៧១ | ចាប វណៈ | ស | ២៤ | នេសាទ | កែប | ១៥/០៩/២០១១ |
| ៧២ | អ៊ួង សុខា | ស | ២៧ | នេសាទ | កែប | ១៥/០៩/២០១១ |
| ៧៣ | ចាប ថេត | ស | ៣៥ | នេសាទ | កែប | ១៥/០៩/២០១១ |
| ៧៤ | រស់ សេរី | ស | ៥៦ | នេសាទ | កែប | ១៥/០៩/២០១១ |
| ៧៥ | រិន ស៊ីន | ស | ២៦ | នេសាទ | កែប | ១៥/០៩/២០១១ |
| ៧៦ | ចាប បូរិន | ស | ៤២ | នេសាទ | កែប | ១៥/០៩/២០១១ |
| ៧៧ | សុខ ឡួន | ស | ៥០ | នេសាទ | កែប | ១៥/០៩/២០១១ |
| ៧៨ | ង៉ែត សុជា | ស | ២៥ | នេសាទ | កែប | ១៥/០៩/២០១១ |
| ៧៩ | ហួង គាន | ស | ៥៣ | នេសាទ | កែប | ១៥/០៩/២០១១ |
| ៨០ | នាក់ ភក្រា | ស | ២៤ | នេសាទ | កែប | ១៥/០៩/២០១១ |
| ៨១ | បូ គីមឡាង | ស | ៥២ | នេសាទ | កែប | ១៥/០៩/២០១១ |
| ៨២ | ជាត សុភី | ស | ២៧ | នេសាទ | កែប | ១៥/០៩/២០១១ |
| ៨៣ | ម៉ៅ ស្រីនាង | ស | ១៩ | នេសាទ | កែម | ១៥/០៩/២០១១ |
| ៨៤ | ម៉ៅ ចាន់រ៉ា | ស | ២៤ | នេសាទ | កែប | ១៥/០៩/២០១១ |
| ៨៥ | ម៉ៅ ចាន់រី | ស | ២៦ | នេសាទ | កែប | ១៥/០៩/២០១១ |
| ៨៦ | ចាប ធឿន | ប | ២៣ | នេសាទ | កែប | ១៥/០៩/២០១១ |

| | | | | | | |
|---|---|---|---|---|---|---|
| ៨៧ | លឹម មេងតែង | ប | ៣៩ | នេសាទ | កែប | ១៥/០៩/២០១១ |
| ៨៨ | ឆោម សួន | ប | ៤៩ | នេសាទ | កែប | ១៥/០៩/២០១១ |
| ៨៩ | ហួង គាន | ស | ៥០ | នេសាទ | កែប | ១៥/០៩/២០១១ |
| ៩០ | ខៃ សៀន | ស | ៥៣ | នេសាទ | កែប | ១៥/០៩/២០១១ |
| ៩១ | កែវ ម៉ែ | ប | ៣៣ | នេសាទ | កែប | ២៦/០៩/២០១១ |
| ៩២ | រិន ស្រីនាត | ស | ១៨ | នេសាទ | កែប | ២៦/០៩/២០១១ |
| ៩៣ | នាក់ វិបុល | ប | ២៦ | នេសាទ | កែប | ២៦/០៩/២០១១ |
| ៩៤ | ង៉ែត ធីម | ស | ៤៦ | នេសាទ | កែប | ២៦/០៩/២០១១ |
| ៩៥ | កែវ មុន្នី | ប | ៣០ | នេសាទ | កែប | ២៦/០៩/២០១១ |
| ៩៦ | អេវ ច្រិប | ស | ៤០ | នេសាទ | កែប | ២៦/០៩/២០១១ |
| ៩៧ | សេង ប៉ាវ | ស | ៣៩ | នេសាទ | កែប | ២៦/០៩/២០១១ |
| ៩៨ | ព្រំ ស៊ីថា | ស | ៤០ | នេសាទ | កែប | ២៦/០៩/២០១១ |
| ៩៩ | ខៀវ ភារិន | ប | ២៤ | នេសាទ | កែប | ២៦/០៩/២០១១ |
| ១០០ | អ៊ុយ ណេង | ប | ៣២ | នេសាទ | កែប | ២៦/០៩/២០១១ |
| ១០១ | ង៉ែត ប៊ុនធឿន | ប | ៣១ | នេសាទ | កែប | ២៦/០៩/២០១១ |
| ១០២ | អ៊ុយ គីមអេង | ស | ២៣ | នេសាទ | កែប | ២៦/០៩/២០១១ |
| ១០៣ | ង៉ែត ប៊ុនណា | ប | ២៤ | នេសាទ | កែប | ២៦/០៩/២០១១ |
| ១០៤ | យី រដ្ឋនា | ប | ១៨ | នេសាទ | កែប | ២៦/០៩/២០១១ |
| ១០៥ | ប៊ុន វណ្ណៈ | ប | ២៥ | នេសាទ | កែប | ២៦/០៩/២០១១ |
| ១០៦ | ឈឹម យ៉ាន | ស | ៦៥ | នេសាទ | កែប | ២៦/០៩/២០១១ |
| ១០៧ | ខាន់ ហ្វី | ប | ២៥ | នេសាទ | កែប | ២៦/០៩/២០១១ |
| ១០៨ | ពៅ នាប | ស | ៣១ | នេសាទ | កែប | ២៦/០៩/២០១១ |
| ១០៩ | យ៉ង ស៊ាន | ប | ៥២ | នេសាទ | កែប | ២៦/០៩/២០១១ |

| | | | | | | |
|---|---|---|---|---|---|---|
| ១១០ | ព្រៃរ៉ុ | ប | ៥៦ | នេសាទ | កែប | ២៦/០៩/២០១១ |
| ១១១ | ទឹម សុខចិន្តា | ស | ១៩ | នេសាទ | កែប | ២៦/០៩/២០១១ |

សរុបចំនួន ១១១នាក់ ស្រ្តី ៤១

បានឃើញ និងបញ្ជាក់ថាឈ្មោះក្នុងបញ្ជីខាងលើនេះ
គឺជាសមាជិកគណៈកម្មការសហគមន៍
នេសាទភូមិកែបពិតប្រាកដមែន ។
ធ្វើនៅភូមិកែប.ថ្ងៃទី...០៥.....ខែ.វិច្ឆិកា ឆ្នាំ២០១១
មេភូមិកែប

ណុប_សំអុន

ធ្វើនៅភូមិកែប ថ្ងៃទី.០៤..ខែវិច្ឆិកា..ឆ្នាំ២០១១
ប្រធានគណៈកម្មការសហគមន៍នេសាទភូមិកែប

កៅ.វី.

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# បញ្ជីគណៈកម្មការសហគមន៍នេសាទភូមិកែប
## សង្កាត់កែប ក្រុងកែប ខេត្តកែប

| ល.រ | ឈ្មោះ | ភេទ | អាយុ | ភូមិ | តួនាទី |
|---|---|---|---|---|---|
| ១ | ចក់ នី | ប្រុស | ៥៧ | កែប | ប្រធានសហគមន៍នេសាទ |
| ២ | អ៊ុយ ទ្រី | ប្រុស | ៥២ | កែប | អនុប្រធាន |
| ៣ | ជួន ឡាន | ប្រុស | ៤៥ | កែប | លេខាធិការ |
| ៤ | ហុង វួចឆេង | ស្រី | ៤០ | កែប | បេឡាធិការ |
| ៥ | ទឹម វ៉ាន់នី | ប្រុស | ២៧ | កែប | អប់រំ ផ្សព្វផ្សាយ |
| ៦ | អៀម ដួរ | ប្រុស | ៤៩ | កែប | ល្បាត |
| ៧ | អ៊ុយ ហេង | ប្រុស | ៤៤ | កែប | ល្បាត |
| ៨ | ចាប វុទ្ធី | ប្រុស | ៣៩ | កែប | ល្បាត |
| ៩ | គេង ចិន | ប្រុស | ៣៤ | កែប | ល្បាត |

ធ្វើនៅភូមិកែប ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១១
ប្រធានគណៈកម្មការសហគមន៍នេសាទភូមិកែប

ចក់.នី

បានឃើញ និងបញ្ជាក់ថា
ឈ្មោះនៅក្នុងប ញ្ជីខាងលើនេះគឺជាសមាជិកគណៈកម្មការ
សហគមន៍នេសាទភូមិកែបពិតប្រាកដមែន ។
ធ្វើនៅកែប ថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ ២០១១
ចៅសង្កាត់កែប

ណុប_សំអុន

## តារាងឧបសម្ព័ន្ធ

### ក. រចនាសម្ព័ន្ធគណៈកម្មការសហគមន៍នេសាទភូមិកែប




### ខ. តួនាទីភារកិច្ចទទួលខុសត្រូវរបស់គណៈកម្មការសហគមន៍នេសាទ

**១-ប្រធានគណៈកម្មការសហគមន៍នេសាទ**

- ដឹកនាំ និងទទួលខុសត្រូវរួមក្នុងការអនុវត្តន៍ការងារនៅក្នុងសហគមន៍នេសាទ
- សម្របសម្រួលការងារជាមួយស្ថាប័នជំនាញ និងអាជ្ញាធរមូលដ្ឋាន ដើម្បីគាំទ្រដល់ការងារសហគមន៍
- ទំនាក់ទំនងជាមួយអង្គការនានា ដើម្បីស្វែងរកជំនួយទ្រទ្រង់សកម្មភាពសហគមន៍នេសាទ
- សម្របសម្រួលដោះស្រាយបញ្ហាផ្សេងៗក្នុងសហគមន៍នេសាទ
- តាមដានត្រួតពិនិត្យរាល់សកម្មភាពការងាររបស់សហគមន៍នេសាទ
- ដឹកនាំរាល់ការប្រជុំ និងមហាសន្និបាតក្នុងការបូកសរុបវាយតម្លៃ និងរៀបចំផែនការការងារ
- ផ្តល់ភាពយុត្តិធម៌ និងតម្លាភាពដល់សមាជិកសហគមន៍។

**២- អនុប្រធានគណៈកម្មការសហគមន៍នេសាទ**

- ចូលរួមអនុវត្តការងារជាមួយប្រធាន
- ជំនួសមុខឱ្យប្រធាននៅពេលអវត្តមាន
- អនុប្រធានទី ១ ទទួលបន្ទុកផ្នែកបេឡាធិការ និង អប់រំ ផ្សព្វផ្សាយ
- អនុប្រធានទី ២ ទទួលបន្ទុកផ្នែកលេខាធិការ និង ផ្នែកល្បាត។
- ទទួលភារកិច្ចផ្សេងៗ ដែលប្រធានប្រគល់ជូន។

៣- លេខាធិការ

- កត់ត្រារាល់សកម្មភាព និងរក្សាទុកដាក់ឯកសារផ្សេងៗរបស់សហគមន៍
- ធ្វើកំណត់ហេតុរាល់ការប្រជុំ និងមហាសន្និបាត របស់សហគមន៍នេសាទ
- រៀបចំលិខិតអញ្ជើញ និងទីកន្លែងប្រជុំ
- ទទួលពាក្យស្នើសុំចូលជាសមាជិក និងលាលែងពីសមាជិក
- កត់ត្រា និងគ្រប់គ្រងសម្ភារៈរបស់សហគមន៍នេសាទ
- រៀបចំបែបបទ និងលិខិតស្នាមផ្សេងៗ ដែលទាក់ទងការគ្រប់គ្រងសហគមន៍
- ទទួលពាក្យបណ្តឹងតវ៉ាផ្សេងៗ
- ព្រាងរបាយការណ៍ពីលទ្ធផលការងាររបស់សហគមន៍នេសាទ ដើម្បីដាក់ជូនប្រធានពិនិត្យ និងសម្រេច

៤- ហេរញ្ញិការ

- ទទួលខុសត្រូវការងារហិរញ្ញវត្ថុរបស់សហគមន៍នេសាទទាំងមូល
- គ្រប់គ្រង និងចុះបញ្ជីគណនេយ្យ របស់សហគមន៍នេសាទឱ្យបានត្រឹមត្រូវតាមប្រព័ន្ធការងារ គណនេយ្យ
- រៀបចំគំរោងផែនការប្រើប្រាស់ហិរញ្ញវត្ថុរបស់សហគមន៍ ដើម្បីគណៈកម្មការសហគមន៍ពិនិត្យ និងសម្រេច
- ធ្វើរបាយការណ៍ និងរាយការណ៍ពីស្ថានភាពចំណូល ចំណាយ ជូនគណៈកម្មការសហគន៍ជារៀងរាល់ខែ
- ស្នើសុំការឯកភាពពីសមាជិកគណៈកម្មការសហគមន៍នេសាទ នូវរាល់ចំណាយផ្សេងៗ និងរក្សាទុកដាក់ ឯកសារឱ្យបានត្រឹមត្រូវ
- រៀបចំបែបបទ និងទទួលប្រាក់សមាជិកភាព និងភាគទានប្រចាំឆ្នាំពីសមាជិក ។

៥- ផ្នែកអប់រំ ផ្សព្វផ្សាយ

- អប់រំ ផ្សព្វផ្សាយពីខ្លឹមសារលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍ ច្បាប់ អនុក្រឹត្យ សេចក្តីជូនដំណឹង និងលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធលើការគ្រប់គ្រងវិស័យជលផល បរិស្ថាន សិទ្ធិមនុស្ស អនាម័យ និង សុខភាព ។ល។ ជូនដល់សមាជិកសហគមន៍របស់ខ្លួន និងសហគមន៍នេសាទជិតខាង
- ស្វែងរកវិធីសាស្ត្រ និងបទពិសោធន៍ល្អៗ សម្រាប់ធ្វើការអប់រំ ផ្សព្វផ្សាយឱ្យរឹតតែមានប្រសិទ្ធភាព
- រៀបចំឯកសារ ផ្លាកសញ្ញា និងរូបភាពផ្សេងៗ សម្រាប់ធ្វើការអប់រំ ផ្សព្វផ្សាយ
- រៀបចំវគ្គបណ្តុះបណ្តាល ទស្សនៈកិច្ចសិក្សា ដើម្បីលើកកំពស់កំរិតយល់ដឹង និងផ្លាស់ប្តូរបទពិសោធន៍ក្នុងការគ្រប់គ្រងធនធានធម្មជាតិ
- ធ្វើរបាយការណ៍ពីលទ្ធផលលើការងារអប់រំ និងការវាយតំលៃផែនការអនុវត្ត ជូនប្រធានគណៈកម្មការសហគមន៍នេសាទជារៀងរាល់ខែ។

៦- ផ្នែកល្បាត

- ទទួលខុសត្រូវលើកិច្ចការការពារធនធានជលផល និងទប់ស្កាត់បទល្មើស ដែលកើតមានក្នុងដែននេសាទសហគមន៍
- ទទួលបន្ទុកពិនិត្យ តាមដាន ឃ្លាំមើល និងល្បាតនូវរាល់សកម្មភាពនេសាទ។ ករណីចាំបាច់ត្រូវរាយការណ៍ព័ត៌មានជូនប្រធានឱ្យបានឆាប់រហ័ស។
- សហការជាមួយសមត្ថកិច្ចជលផល បង្ក្រាបរាល់បទល្មើសជលផល នៅក្នុងកន្លែងនេសាទសហគមន៍។ ក្នុងករណីបន្ទាន់ និងចាំបាច់ ផ្នែកល្បាតសហគមន៍នេសាទអាចស្នើសុំអន្តរាគមន៍ពីសមត្ថកិច្ចនៅជិតខាងអាជ្ញាធរ ដែនដី ដើម្បីឃាត់ទុកវត្ថុតាងនៃបទល្មើស និងឃាត់ខ្លួនជនល្មើស រួចបញ្ជូនភ្លាមបន្ទាន់ទៅសមត្ថកិច្ចជលផល ដើម្បីធ្វើការដោះស្រាយបទល្មើសទៅតាមច្បាប់

- រៀបចំផែនការល្បាត និងចាត់វិធានការការពារធនធានធម្មជាតិក្នុងកន្លែងនេសាទសហគមន៍ ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាព
- តាមដាន ស្រាវជ្រាវ និងត្រួតពិនិត្យអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ ដែលចូលរកនេសាទក្នុងកន្លែងនេសាទសហគមន៍
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលសកម្មភាពការងាររបស់ខ្លួន ជូនប្រធានគណៈកម្មការសហគមន៍នេសាទរៀងរាល់ខែ។

ធ្វើនៅភូមិកែប ថ្ងៃទី ៦ ខែ ៧ ឆ្នាំ ២០១១

**ប្រធានគណៈកម្មការសហគមន៍នេសាទភូមិកែប**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# លក្ខន្តិកៈសហគមន៍នេសាទ

# ភូមិកែប

ឈ្មោះសហគមន៍នេសាទ : ភូមិកែប
ភូមិ : កែប
សង្កាត់ : កែប
ក្រុង : កែប
ខេត្ត : កែប

# ជំពូកទី ១
## គោលបំណង និងនាមករណ៍

**ប្រការ ១.-**

លក្ខន្តិកៈនេះមានគោលបំណង ÷

- កំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការការពារ ការអភិរក្ស ការអភិវឌ្ឍន៍ និងការប្រើប្រាស់ធនធាន ជលផលរបស់សហគមន៍នេសាទប្រកបដោយនិរន្តរភាព
- ធ្វើជាគោលការណ៍គ្រឹះ និងជាយន្តការសម្រាប់ដំណើរការសហគមន៍នេសាទ
- ការពារសិទ្ធិ និងផលប្រយោជន៍របស់សមាជិកសហគមន៍នេសាទ និងផលប្រយោជន៍សាធារណៈ។

**ប្រការ ២ .-**

ឈ្មោះសហគមន៍នេសាទភូមិកែប ហៅកាត់ថា ៖ ស.ន.ភ.ក មានអាសយដ្ឋានស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប ។

សហគមន៍នេសាទនេះមានការចូលរួមពីប្រជាពលរដ្ឋដែលរស់នៅក្នុង ៖

ភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប ។

មានកម្មវត្ថុ ៖ ដើម្បីការពារ ប្រើប្រាស់ អភិរក្ស អភិវឌ្ឍន៍ ធនធានជលផលឱ្យបានយូរអង្វែង ។

# ជំពូកទី ២
## លក្ខខណ្ឌនៃការសុំចូលជាសមាជិក ភារកិច្ច និងសិទ្ធិរបស់សមាជិក

**ប្រការ ៣.-**

ប្រជាពលរដ្ឋទាំងពីរភេទ ដែលមានបំណងចង់ចូលជាសមាជិកសហគមន៍នេសាទ មានសិទ្ធិដាក់ពាក្យសុំចូល ដោយស្ម័គ្រចិត្ត និងត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ៖

- មានលំនៅដ្ឋាននៅក្នុងបណ្ដាភូមិនៃសហគមន៍នេសាទ
- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ ឆ្នាំឡើង។

**ប្រការ ៤.-**

សមាជិកសហគមន៍នេសាទដែលបានបំពេញលក្ខខណ្ឌក្នុងប្រការ ៣ ខាងលើមានសិទ្ធិ ៖

- ចូលរួមប្រជុំមហាសន្និបាត និងបោះឆ្នោតស្មើភាពគ្នា
- បោះឆ្នោត និងឈរឈ្មោះជាបេក្ខជននៃគណៈកម្មការសហគមន៍នេសាទ ស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ
- ទទួលព័ត៌មានអំពីស្ថានភាពសេដ្ឋកិច្ចសង្គមរបស់សហគមន៍នេសាទពីគណៈកម្មការសហគមន៍នេសាទ
- ស្នើឱ្យមានការកោះប្រជុំមហាសន្និបាតវិសាមញ្ញ ដើម្បីធ្វើការពិភាក្សា និងសម្រេចលើបញ្ហាណាមួយ បើមានការស្នើសុំពីសមាជិកយ៉ាងតិចមួយភាគបី (១/៣)នៃសមាជិកសហគមន៍នេសាទទាំងអស់
- ធ្វើនេសាទជាលក្ខណៈគ្រួសារស្របតាមច្បាប់ស្ដីពីជលផល កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមននិងលិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធនឹងជលផល

- ចូលរួមក្នុងសកម្មភាពទាំងអស់របស់សហគមន៍នេសាទ
- ប្តឹងតវ៉ា ឬផ្តល់ព័ត៌មានអំពីបាតុភាពទាំងឡាយ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សហគមន៍ទៅសមត្ថកិច្ចរដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធ
- ទទួលការគាំទ្រពីមជ្ឈដ្ឋាននានាដើម្បីផលប្រយោជន៍របស់សហគមន៍។

សមាជិកសហគមន៍នេសាទត្រូវទទួលខុសត្រូវរាល់សកម្មភាពរៀងៗខ្លួន និងរួមគ្នាចំពោះកំហុសដែលខ្លួនបាន ប្រព្រឹត្តក្នុងពេលបំពេញភារកិច្ច ដោយមិនទាន់គិតដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ។

សមាជិកសហគមន៍នេសាទចំនួនមួយភាគដប់(១/១០)ឡើងទៅអាចស្នើសុំឱ្យប្រធានគណៈកម្មការសហគមន៍នេសាទបញ្ចូលបញ្ហាមួយចំនួនទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទសាមី ហើយចំនួនសមាជិក សហគមន៍នេសាទដែលបានស្នើសុំខាងលើនេះអាចចាត់តំណាងចំនួនបី (៣)នាក់ចូលរួមប្រជុំ ដើម្បីចោទសួរគណៈកម្មការសហគមន៍នេសាទនូវបញ្ហាទាំងឡាយណាដែលទាក់ទងនឹងចំណុចដែលបានស្នើឡើងនោះ។

ប្រការ ៥.-

សមាជិកសហគមន៍នេសាទមានកាតព្វកិច្ច និងភារកិច្ចដូចខាងក្រោម ៖
- អនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីជលផល
- អនុវត្តតាមព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- អនុវត្តតាមអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ និងលិខិតបទដ្ឋានផ្សេងៗទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ
- អនុវត្តតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- អនុវត្តតាមសេចក្តីសម្រេចរបស់មហាសន្និបាត និងគណៈកម្មការសហគមន៍នេសាទ
- បង់ប្រាក់សមាជិកភាពចំនួន ១០០០ រៀល តាមការសម្រេចរបស់មហាសន្និបាត នៅពេលដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ
- បង់ប្រាក់ភាគទានប្រចាំឆ្នាំចំនួន ១២០០ រៀល តាមការសម្រេចរបស់មហាសន្និបាត
- ចូលរួមក្នុងសកម្មភាពរបស់សហគមន៍នេសាទដើម្បីផលប្រយោជន៍ និងការរីកចំរើនរបស់សហគមន៍នេសាទ
- ចូលរួមការពារ ថែរក្សា និងគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទ
- ចូលរួមឃ្លាំមើល ទប់ស្កាត់ និងរាយការណ៍រាល់សកម្មភាពបទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍។

## ជំពូកទី ៣

### លក្ខណៈវិនិច្ឆ័យ លក្ខខណ្ឌនៃការលាឈប់ និងការបណ្តេញចេញពីសមាជិកភាព

ប្រការ ៦.-

សមាជិកសហគមន៍នេសាទ មានសិទ្ធិលាឈប់ពីសមាជិកភាពបានដោយ ៖

-ដាក់ពាក្យសុំលាលែងជាលាយលក្ខណ៍អក្សរ
-ការផ្លាស់ប្តូរទីលំនៅចេញពីកន្លែងនេសាទសហគមន៍
-សាមីខ្លួនទទួលមរណភាព
-សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច ។

**ប្រការ ៧.-**

សមាជិកសហគមន៍អាចត្រូវបណ្តេញចេញពីសមាជិកភាពក្នុងលក្ខខណ្ឌដូចខាងក្រោម ៖
-សាមីខ្លួនបានប្រព្រឹត្តផ្ទុយនឹងលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ។
-ការមិនបង់ភាគទានចំនួន ៣ លើកជាប់ៗគ្នា
-ការធ្វើឱ្យប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍នៃសហគមន៍នេសាទ ឬសមាជិកសហគមន៍នេសាទដទៃទៀត
-សាមីខ្លួនត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម

## ជំពូកទី ៤
## របៀបរបបកាន់បញ្ជី និង ឯកសារនានា

**ប្រការ ៨.-**

ប្រភពហិរញ្ញវត្ថុរបស់សហគមន៍នេសាទបានមកពី ៖
-ភាគទានរបស់សមាជិកសហគមន៍នេសាទ
-អំណោយពីសប្បុរសជន
-ជំនួយពីរាជរដ្ឋាភិបាល អង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល
-ចំណូលស្របច្បាប់ផ្សេងៗទៀត។

**ប្រការ ៩.-**

រាល់ការចំណាយថវិកា សហគមន៍ត្រូវអនុវត្តដូចតទៅ ៖
-ការចំណាយពី ១០០រៀល (មួយរយរៀល) ដល់ ៥០.០០០រៀល (ប្រាំម៉ឺនរៀល) ត្រូវសម្រេចដោយប្រធានគណៈកម្មការសហគមន៍នេសាទ
-ការចំណាយពី ៥០.១០០រៀល (ប្រាំម៉ឺនមួយរយរៀល) ដល់ ៨០.០០០រៀល (ប្រាំបីម៉ឺនរៀល) ត្រូវសម្រេចដោយគណៈកម្មការសហគមន៍នេសាទ
-ការចំណាយចាប់ពី ៨០.១០០ រៀល (ប្រាំបីម៉ឺនមួយរយរៀល)ឡើងទៅ ត្រូវសម្រេចដោយមហាសន្និបាត។

**ប្រការ ១០.-**

សហគមន៍នេសាទត្រូវតម្កល់ទុកឯកសារ និងរៀបចំឱ្យមានបញ្ជី ៖
-ចំណូល ចំណាយថវិកា
-សារពើភណ្ឌ
-សមាជិកសហគមន៍នេសាទ
-កំណត់ហេតុប្រជុំមហាសន្និបាតសហគមន៍នេសាទ

-កំណត់ហេតុប្រជុំគណៈកម្មការសហគមន៍នេសាទ

-ឯកសារដទៃទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ។

**ប្រការ ១១.-**

ការគ្រប់គ្រង និងប្រើប្រាស់ថវិកា ៖

-ការគ្រប់គ្រងថវិកា ត្រូវមានការកាន់បញ្ជីគណនេយ្យ

-ថវិកាចំណូលដែលទទួលបានពីប្រភពផ្សេងៗ ត្រូវរក្សាទុកក្នុងបេឡារបស់សហគមន៍នេសាទ

-រាល់ថវិកាចំណាយ ត្រូវមានរបាយការណ៍ទូទាត់ដោយមានសក្ខីបត្រ និងចុះបញ្ជីឱ្យបានត្រឹមត្រូវ

-ថវិកាដែលត្រូវចំណាយ គឺសម្រាប់តែបម្រើឱ្យការងារគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍សហគមន៍នេសាទ។

## ជំពូកទី ៥
## គណៈកម្មការសហគមន៍នេសាទ

**ៈរ ១២.-**

សមាសភាពគណៈកម្មការសហគមន៍នេសាទរួមមាន ប្រធាន អនុប្រធាន និងសមាជិក។ គណៈកម្មការសហគមន៍នេសាទត្រូវបោះឆ្នោតជ្រើសរើសសមាជិកទទួលបន្ទុកលេខាធិការមួយរូប និងសមាជិកទទួលបន្ទុកហិរញ្ញិក មួយរូប និងត្រូវពិភាក្សាបែងចែកភារកិច្ចសមាជិកផ្សេងទៀតតាមការជាក់ស្តែង។

ប្រធានគណៈកម្មការសហគមន៍នេសាទទទួលខុសត្រូវដឹកនាំ និងគ្រប់គ្រងសហគមន៍នេសាទទាំងមូល។ អនុប្រធានគណៈកម្មការសហគមន៍នេសាទជាជំនួយការឱ្យប្រធាន។

**ប្រការ ១៣.-**

គណៈកម្មការសហគមន៍នេសាទមានអាណត្តិប្រាំ (៥)ឆ្នាំ ចាប់ពីថ្ងៃបោះឆ្នោត ហើយផុតកំណត់នៅពេលដែល មានគណៈកម្មការសហគមន៍នេសាទថ្មីដែលត្រូវបានបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាតឱ្យចូលកាន់តំណែងជំនួស។ ក្នុងករណី ដែលសហគមន៍នេសាទដំណើរការមិនប្រក្រតី ដោយមូលហេតុដំណើរការមិនល្អ ឬអសមត្ថភាពក្នុង ការគ្រប់គ្រងសហគមន៍នេសាទ សមាជិកសហគមន៍នេសាទចំនួនមួយភាគបី (១/៣) មានសិទ្ធិស្នើសុំបើកមហាសន្និបាត វិសាមញ្ញដើម្បីបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទជាថ្មី។

**ប្រការ១៤.-**

ក្នុងករណីដែលសមាជិកគណៈកម្មការសហគមន៍នេសាទណាម្នាក់អវត្តមាន ដោយគ្មានមូលហេតុរយៈពេលបីមួយ (៣)ខែ ឬសុំលាលែងមុនចប់អាណត្តិ បេក្ខជនដែលមានឈ្មោះតាមសម្លេងគាំទ្របន្ទាប់ក្នុងពេលបោះឆ្នោត ជ្រើសរើសក្នុងមហាសន្និបាតកន្លងមក ត្រូវបានជ្រើសតាំងជំនួស។



# ជំពូកទី ៦

## របៀបរបបប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ

**ប្រការ ១៥.-**

គណៈកម្មការសហគមន៍នេសាទត្រូវកំណត់របបប្រជុំឱ្យបានទៀងទាត់រៀងរាល់ខែ។ កិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទអាចប្រព្រឹត្តទៅបាន លុះត្រាតែមានសមាជិកគណៈកម្មការចូលរួមយ៉ាងតិចចំនួន ២/៣ (ពីរភាគបី) នៃសមាសជិករបស់គណៈកម្មការសហគមន៍នេសាទទាំងមូល។

**ប្រការ ១៦.-**

ប្រធានគណៈកម្មការសហគមន៍នេសាទជាអ្នកកោះអញ្ជើញ និងធ្វើជាប្រធានគ្រប់កិច្ចប្រជុំ។ ក្នុងករណីប្រធានគណៈកម្មការសហគមន៍នេសាទអវត្តមាន អនុប្រធានដែលត្រូវបានប្រគល់សិទ្ធិត្រូវធ្វើជាប្រធានអង្គប្រជុំ។ រាល់ការប្រជុំ ត្រូវមានកំណត់ហេតុ និងបញ្ជីវត្តមានច្បាស់លាស់។

ប្រធានអង្គប្រជុំ ត្រូវធានាឱ្យគ្រប់កិច្ចប្រជុំសហគមន៍នេសាទប្រព្រឹត្តទៅដោយលក្ខណៈប្រជាធិបតេយ្យ រៀបរយ និងគ្មានការរំខាន។

ប្រធានអង្គប្រជុំ អាចបណ្តេញសមាជិកអង្គប្រជុំណាម្នាក់ចេញពីកិច្ចប្រជុំបាន ក្នុងករណីដែលសមាជិកនោះធ្វើឱ្យ ខូចសណ្តាប់ធ្នាប់អង្គប្រជុំ។

**ប្រការ ១៧ .-**

ការសម្រេចលើបញ្ហាណាមួយ របស់សហគមន៍ដូចមានចែងខាងក្រោមនេះគឺ ត្រូវអនុម័តដោយកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ ដោយមានសម្លេងគាំទ្រយ៉ាងតិចលើសពីពាក់កណ្តាលនៃចំនួនសមាជិក ការ សហគមន៍នេសាទដែលមានវត្តមានក្នុងអង្គប្រជុំ។ ក្នុងករណីដែលមានសំលេងស្មើគ្នា មតិប្រធានអង្គប្រជុំជាឧត្តមានុភាព ៖

-សេចក្តីព្រាងកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
-សេចក្តីព្រាងគម្រោងថវិកា ចំណូល និងចំណាយក្នុងសហគមន៍នេសាទ
-ការព្យួរសមាជិកភាពរបស់សមាជិកដែលមានកំហុស
-ការទទួលពាក្យសុំចូលជាសមាជិកថ្មី
-ការដាក់ទណ្ឌកម្មតាមបទបញ្ជាផ្ទៃក្នុង ដល់សមាជិកសហគមន៍នេសាទ។

បន្ទាប់ពីកិច្ចប្រជុំចប់ភ្លាម ប្រធានគណៈកម្មការសហគមន៍នេសាទ ត្រូវចាត់ឱ្យធ្វើការជូនដំណឹងដល់សមាជិក សហគមន៍នេសាទអំពីសេចក្តីសម្រេចរបស់ខ្លួន។ សេចក្តីសម្រេចនៃអង្គប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការសហគមន៍នេសាទ ឬសាលាឃុំ សង្កាត់ក្នុងរយៈពេល ៧ ថ្ងៃយ៉ាងយូរបន្ទាប់ពីការប្រជុំ។

# ជំពូកទី ៧
# មហាសន្និបាតសហគមន៍នេសាទ

**ប្រការ ១៨.-**

មហាសន្និបាតសហគមន៍នេសាទជាអង្គប្រជុំកំពូល ដើម្បីធ្វើការអនុម័ត និងធ្វើសេចក្តីសម្រេចទាំងឡាយក្នុងនាមសហគមន៍នេសាទ។ មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទត្រូវប្រារព្ធធ្វើឡើង បន្ទាប់ពីក្រុមស្ថាបនិក បានរៀបចំរួចរាល់នូវកិច្ចការទាំងឡាយដែលពាក់ព័ន្ធនឹងដំណើរការមហាសន្និបាត។

ការកោះប្រជុំមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ ធ្វើឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានការជួយសម្របសម្រួលពីសមត្ថកិច្ចរដ្ឋបាលជលផល តាមការស្នើសុំរបស់ក្រុមស្ថាបនិក ហើយត្រូវមានការចូលរួមពីសមាជិក ដែលបានដាក់ពាក្យស្នើសុំរួចមកហើយ។

មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ អនុម័តនូវសេចក្តីសម្រេច និងកិច្ចការសំខាន់ដូចខាងក្រោមម ៖

-អ្នកដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ

-ឈ្មោះសហគមន៍នេសាទ

-លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

-ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ។

**ប្រការ ១៩.-**

មហាសន្និបាតសាមញ្ញត្រូវរៀបចំឡើង ១ ឆ្នាំម្តង ដើម្បីសរុបលទ្ធផលការងារប្រចាំឆ្នាំ និងអនុម័តនូវកិច្ចការ សំខាន់ៗរបស់សហគមន៍នេសាទ។ ក្នុងករណីចាំបាច់ សហគមន៍អាចរៀបចំមហាសន្និបាតវិសាមញ្ញតាមការស្នើសុំពីសមាជិក សហគមន៍នេសាទចំនួនមួយភាគបី (១/៣)យ៉ាងតិច។

**ប្រការ ២០.-**

គណៈកម្មការសហគមន៍នេសាទអាចអញ្ជើញរដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ សង្កាត់ សមត្ថកិច្ចពាក់ព័ន្ធ និងអ្នកគាំទ្រចូលរួមសង្កេតការណ៍ ឬសម្របសម្រួល ឬជាកិត្តិយសក្នុងមហាសន្និបាតសហគមន៍នេសាទ។

**ប្រការ ២១.-**

លក្ខខណ្ឌនៃដំណើរការមហាសន្និបាតមានដូចខាងក្រោម ៖

-ត្រូវធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងជាសាធារណៈ និងបិទប្រកាសនៅសាលាឃុំសង្កាត់ និងទីស្នាក់ការសហគមន៍នេសាទ

-ការកោះអញ្ជើញសមាជិកសហគមន៍នេសាទឱ្យចូលរួមមហាសន្និបាតសាមញ្ញត្រូវធ្វើឡើងដប់ (១០) ថ្ងៃយ៉ាងតិច មុនថ្ងៃបើកមហាសន្និបាត និងបី (៣)ថ្ងៃយ៉ាងតិចមុនថ្ងៃមហាសន្និបាតវិសាមញ្ញ

-មហាសន្និបាតសាមញ្ញ ឬវិសាមញ្ញអាចប្រជុំពិភាក្សាអនុម័ត និងសម្រេចបានលុះត្រាតែមានវត្តមានលើស ពីពាក់កណ្តាលនៃចំនួនសមាជិកសហគមន៍នេសាទ

-អង្គ ប្រជុំមហាសន្និបាតដឹកនាំដោយប្រធានគណៈកម្មការសហគមន៍នេសាទ ឬប្រធានអង្គប្រជុំ ដែលជ្រើ សរើសដោយការអនុម័តក្នុងចំណោមសមាជិកវត្តមាន

-មហាសន្និបាតត្រូវអនុម័តលេខាកត់ត្រា ដើម្បីធ្វើកំណត់ហេតុ សេចក្ដីសម្រេច និងបញ្ជីវត្តមាន
-លេខាកត់ត្រា និងប្រធានអង្គប្រជុំត្រូវចុះហត្ថលេខាលើកំណត់ហេតុ
-សមាជិកម្នាក់មានសំឡេងតែមួយគត់ ហើយមិនអាចបញ្ជូនមនុស្សមកតំណាងបានទេ
-សេចក្ដីសម្រេចរបស់មហាសន្និបាត ត្រូវយកសំឡេងលើសពីពាក់កណ្ដាល នៃចំនួនសមាជិកដែលមានវត្តមាន។

**ប្រការ ២២.-**

មហាសន្និបាតអនុម័ត ៖
-សេចក្ដីសម្រេចដូចមានចែងក្នុងប្រការ ១៨ កថាខណ្ឌទី ៣ នៃលក្ខន្តិកៈនេះ
-កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
-តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
-ការសុំលាលែង ឬការបណ្ដេញចេញពីសមាជិកភាព ឬពីសមាជិកគណៈកម្មការសហគមន៍នេសាទ
-របាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មការសហគមន៍នេសាទ
-គម្រោងចំណូល ចំណាយរបស់សហគមន៍នេសាទ។

## ជំពូកទី ៨
## ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ

**ប្រការ ២៣.-**

ចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទ និងចំនួនបេក្ខជនឈរឈ្មោះត្រូវអនុម័តដោយមហាសន្និបាត។

**ប្រការ ២៤.-**

កិច្ចដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ គឺជាភារកិច្ចរបស់គណៈកម្មការរៀបចំការ បោះឆ្នោត ដែលអនុម័តដោយមហាសន្និបាត ។ គណៈកម្មការរៀបចំការបោះឆ្នោតមានសមាសភាពពីបី (៣) ទៅប្រាំ (៥)នាក់ ដែលមានប្រធាន អនុប្រធាន និងសមាជិកតាមការកំណត់ជាក់ស្ដែងរបស់មហាសន្និបាត និងត្រូវមានលក្ខណៈ សម្បត្តិគ្រប់គ្រាន់ មានចំណេះដឹង និងមានសីលធម៌ល្អ។ គណៈកម្មការរៀបចំការបោះឆ្នោតត្រូវធ្វើការប្ដេជ្ញាចិត្តបង្ហាញពីភាព ស្មោះត្រង់។

**ប្រការ ២៥.-**

គណៈកម្មការរៀបចំការបោះឆ្នោតមានភារកិច្ចដូចខាងក្រោម ៖
-ប្រកាសបេក្ខជនឈរឈ្មោះ
-ណែនាំអំពីនីតិវិធីនៃការបោះឆ្នោត
-បង្ហាញរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
-រាប់សន្លឹកឆ្នោត និងសរុបលទ្ធផលជូនគណៈអធិបតីដើម្បីប្រកាសជូនមហាសន្និបាត
-ភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ បន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតចប់ជាស្ថាពរ។

**ប្រការ ២៦.-**

បេក្ខជនដែលទទួលបានសំឡេងឆ្នោតគាំទ្រច្រើនជាងគេបង្អស់ គឺជាប្រធានគណៈកម្មការសហគមន៍នេសាទ។ បេក្ខជនដែលទទួលបានសន្លឹកឆ្នោតបន្តបន្ទាប់ត្រូវទទួលតួនាទីជាអនុប្រធានជាសមាជិកគណៈកម្មការសហគមន៍នេសាទ តាមលំដាប់លំដោយ។ ក្នុងករណីបេក្ខជនដែលមានសំឡេងគាំទ្រស្មើគ្នា ត្រូវជ្រើសរើសស្ត្រី ឬបោះឆ្នោតរកអ្នកដែល មានសមត្ថភាព ដោយលើកដៃយកមតិលើសពីពាក់កណ្តាលនៃចំនួនសមាជិកសហគមន៍នេសាទដែលចូលរួម។

## ជំពូកទី ៩
## លក្ខខណ្ឌនៃការរំសាយសហគមន៍នេសាទ និង នីតិវិធីដោះស្រាយវិវាទ

**ប្រការ ២៧.-**

ការរំសាយសហគមន៍នេសាទត្រូវផ្អែកតាម ៖

-សំណើរបស់ខណ្ឌរដ្ឋបាលជលផល នៅពេលដែលពិនិត្យឃើញថា មានការរំលោភធ្ងន់ធ្ងរលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ។

-សេចក្តីសម្រេចមហាសន្និបាតក្រោយពីរំសាយសហគមន៍នេសាទ ទ្រព្យសម្បត្តិរបស់សហគមន៍ ត្រូវចាត់ចែងតាមការអនុម័តរបស់មហា សន្និបាត លើកលែងតែដែននេសាទដែលត្រូវប្រគល់ជូនរដ្ឋវិញ ។

**ប្រការ ២៨.-**

ក្នុងករណីមានការតវ៉ាចោទប្រកាន់ថា ដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទមានភាព មិនប្រក្រតី អ្នកតវ៉ាត្រូវបង្ហាញភស្តុតាងឱ្យបានច្បាស់លាស់អំពីភាពមិនប្រក្រតីនោះភ្លាម នៅមុនពេលប្រកាសលទ្ធផល បោះឆ្នោត ដើម្បីទុកលទ្ធភាពជូនមហាសន្និបាតពិនិត្យ និងសម្រេច។

**ប្រការ ២៩.-**

វិវាទទាំងឡាយនៅក្នុងសហគមន៍នេសាទ ត្រូវដោះស្រាយដូចខាងក្រោម ÷

- គណៈកម្មការសហគមន៍នេសាទត្រូវសម្រុះសម្រួល និងដោះស្រាយរាល់វិវាទដែលកើតមានឡើងនៅក្នុងសហគមន៍នេសាទរបស់ខ្លួន ។

- ក្នុងករណីគណៈកម្មការសហគមន៍នេសាទ ដោះស្រាយវិវាទនោះពុំបានសម្រេច ត្រូវបញ្ជូនសំណុំរឿងនោះទៅសមត្ថកិច្ចរដ្ឋបាលជលផលដើម្បីដោះស្រាយទៅតាមឋានានុក្រម ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធតាមការចាំបាច់។

- ក្នុងករណីដែលបញ្ហាវិវាទនោះនៅតែមិនអាចដោះស្រាយបាន គណៈកម្មការសហគមន៍នេសាទ និងរដ្ឋបាលជលផលត្រូវបញ្ជូនសំណុំរឿងទៅតុលាការខេត្ត ក្រុងសាមីដើម្បីដោះស្រាយតាមផ្លូវច្បាប់។

**ប្រការ ៣០.-**

សមាជិកសហគមន៍នេសាទរូបណាដែលមិនគោរពតាមលក្ខន្តិកៈសហគមន៍នេសាទនេះ ត្រូវទទួលទណ្ឌកម្មពី គណៈកម្មការសហគមន៍នេសាទ ឬមហាសន្និបាតសហគមន៍នេសាទ ទៅតាមកម្រិតនៃទោសកំហុសរបស់ខ្លួន។

## ជំពូកទី ១០
## នីតិវិធីនៃការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

**ប្រការ ៣១.-**

ការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទត្រូវសម្រេចដោយមហាសន្និបាត។ ការលើកសំណើកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទត្រូវធ្វើឡើង ដោយសមាជិកយ៉ាងតិចមួយភាគបី (១/៣) នៃសមាជិកសហគមន៍នេសាទទាំងអស់ ហើយសំណើនេះត្រូវដាក់ជូនគណៈកម្មការសហគមន៍នេសាទមួយខែមុនបើកមហា សន្និបាត។ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងនេះអាចកែប្រែបាន លុះត្រាតែមានសំឡេងយល់ព្រមលើសពីពាក់កណ្តាល នៃ សមាជិកមហាសន្និបាតសហគមន៍នេសាទ។

## ជំពូកទី ១១
## អវសានប្បញ្ញត្តិ

**ប្រការ ៣២.-**

លក្ខន្តិកៈសហគមន៍នេសាទនេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទលើកដំបូង នៅថ្ងៃទី........ខែ......... ឆ្នាំ២០...... និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខារបស់ប្រធានគណៈកម្មការសហគមន៍នេសាទ។

ធ្វើនៅភូមិកែប ថ្ងៃទី.....៧... ខែ.....១..ឆ្នាំ ២០១១

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

# ទបញ្ហាផ្ទៃក្នុងសហគមន៍នេសាទភូមិកែប

# បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

ដើម្បីធានាការគ្រប់គ្រងសហគមន៍នេសាទឱ្យប្រព្រឹត្តទៅមានប្រសិទ្ធភាព និងមានរបៀបរៀបរយល្អ សហគមន៍នេសាទ ភូមិកែប សម្រេចដាក់ចេញនូវបទបញ្ជាផ្ទៃក្នុងដូចខាងក្រោម ៖

**ប្រការ ១.-**

គណៈកម្មការ និងសមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវមានការស្មោះត្រង់ សាមគ្គីឯកភាពផ្ទៃក្នុងជួយស្ថាបនា ព្រមទាំងចូលរួមរៀនសូត្របច្ចេកទេសផ្សេងៗ សម្រាប់បម្រើឱ្យការរីកចម្រើនរបស់សហគមន៍នេសាទ។

**ប្រការ ២.-**

គណៈកម្មការ សមាជិកសហគមន៍នេសាទ ឬបុគ្គលណា ដែលបានកេងប្រវ័ញ្ចធ្វើឱ្យខូចខាត ឬបាត់បង់ទ្រព្យ និងផលប្រយោជន៍សហគមន៍នេសាទ ត្រូវទទួលទណ្ឌកម្មដូចខាងក្រោមនេះ ៖

- ចំពោះសមាជិកសហគមន៍នេសាទ ឬបុគ្គលដទៃទៀតត្រូវសង ឬទូទាត់ទៅតាមទំហំនៃការខូចខាតជាក់ស្តែងតាមការសម្រេចរបស់អង្គប្រជុំគណៈកម្មការសហគមន៍នេសាទ។ក្នុងករណីមិនព្រមសងត្រូវដាក់ជូនមហាសន្និបាតសម្រេច
- ចំពោះគណៈកម្មការសហគមន៍នេសាទត្រូវសង ឬទូទាត់សងការខូចខាត តាមការសម្រេចរបស់មហាសន្និបាតប្រសិនបើនីតិវិធីខាងលើនេះនៅតែមិនអាចដោះស្រាយបានគឺត្រូវអនុវត្តតាមផ្លូវច្បាប់និងបទបញ្ញាជាធរមាន។

**ប្រការ ៣ .-**

សមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវតែចូលរួមមហាសន្និបាត និងរាល់កិច្ចប្រជុំរបស់សហគមន៍នេសាទតាមការ កោះអញ្ជើញរបស់ប្រធានគណៈកម្មការសហគមន៍នេសាទ។ ក្នុងករណីដែលសមាជិកសហគមន៍ណាមិនបានមកចូលរួមប្រជុំចំនួន ៣ ដង ជាប់គ្នាដោយគ្មានមូលហេតុច្បាស់លាស់ ត្រូវទទួលការណែនាំពីគណៈកម្មការសហគមន៍នេសាទ។

ករណី នៅតែមិនរាងចាលគណៈកម្មការត្រូវធ្វើសំណើទៅមហាសន្និបាតសម្រេចដើម្បីបញ្ឈប់ពីសមាជិកភាព។

**ប្រការ ៤.-**

សិទ្ធិដាក់ទណ្ឌកម្ម ៖

**ក-គណៈកម្មការសហគមន៍នេសាទ**

- អប់រំណែនាំលើកទី១ លើកទី២ និងលើកទី៣
- ព្រមាននផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ
- ព្យួរសមាជិកភាពរបស់សមាជិកសហគមន៍នេសាទ ដែលមានកំហុសពី ០១ (មួយ)ខែ ទៅ ០៣ (បី)ខែ ក្នុង ករណីមិនរាងចាលត្រូវបណ្តេញចេញពីសមាជិកភាព
- បញ្ជូនបញ្ហាទំនាស់ទៅមហាសន្និបាតសម្រេច

- ផ្ដាកការនេសាទ ធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅសមត្ថកិច្ចរដ្ឋបាលជលផល ចំពោះការនេសាទលើសទំហំ ចំនួន និងខុសប្រភេទ ពេលវេលា ទីតាំងតាមការកំណត់នៅក្នុងផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀង នៅក្នុងកន្លែងនេសាទសហគមន៍ ។

## ខ-មហាសន្និបាត

- អនុម័តការបណ្ដេញចេញដូចមានចែងក្នុងប្រការ ៧ នៃលក្ខន្តិកៈសហគមន៍នេសាទ
- សម្រេចលើសំណងការខូចខាតទ្រព្យសម្បត្តិសហគមន៍នេសាទ
- សម្រេចដាក់ទណ្ឌកម្មដល់គណៈកម្មការ
- ដាក់ទណ្ឌកម្មដល់សមាជិក ឬបុគ្គលដទៃ ដែលគណៈកម្មការមិនអាចដោះស្រាយបាន។

## ប្រការ ៥.-

សមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវរាយការណ៍ជូនគណៈកម្មការសហគមន៍នេសាទអំពីសំភារៈឧបករណ៍ នេសាទ ដែលគ្រួសារនីមួយៗប្រើប្រាស់នៅក្នុងកន្លែងនេសាទសហគមន៍។

ក្នុងករណីសមាជិកសហគមន៍ណា ប្រើប្រាស់ឧបករណ៍ខុសច្បាប់ ត្រូវទទួលទោសចំពោះមុខច្បាប់ ...ផ្សំគំនិត ជាមួយជនល្មើស ត្រូវទទួលទោសលើសអ្នកប្រព្រឹត្ត ។

## ប្រការ ៦.-

ក- សមាជិកសហគមន៍នេសាទ អាចប្រើប្រាស់ឧបករណ៍នេសាទ ជាលក្ខណៈគ្រួសារ ដូចមានចែង ដូចខាងក្រោម ៖

| ល.រ | ឈ្មោះឧបករណ៍នេសាទ | ក្រឡា | ចំនួន/ប្រវែង |
|---|---|---|---|
| ១ | មងក្ដាម | ៥-៦ ស.ម | ១០០-២០០ ម |
| ២ | មងត្រីក្បក | ៣.៨-៤ស.ម | ១០០-២០០ម |
| ៣ | មងត្រីកន្ធាំង | ៤-៥ ស.ម | ១០០-២០០ ម |
| ៤ | មងបង្កា | ៣-៣.៥ ស.ម | ១០០-២០០ ម |
| ៥ | មងប៉ីជាន | ៣-១០ ស.ម | ២០ដៃ= ១០០០ម |
| ៦ | មងត្រីផ្ទោង | ២ -២.៥ ស.ម | ១០០-២០០ ម |
| ៧ | លបក្ដាម | ៥-៦ ស.ម | ២០០-៣០០ លប |
| ៨ | លបត្រី | ឬស្សី | ១០-៣០ លប |
| ៩ | កន្ទ្រងជងជពុល | ១០-២០ ស.ម | ២កន្ទ្រង/ទូក |
| ១០ | ឈ្មួញរុញដៃ | ១.២-១.៣ ស.ម | ៤-៥ ម (មាត់) |
| ១១ | ជិក កញ្ជ្រៀវ | ចបជីក | មិនកំណត់ |
| ១២ | រាវក្រែង និងចាប់ក្ដាមដោយដៃ | មិនកំណត់ | មិនកំណត់ |

❖ ចំពោះទំហំ ក្រឡា និងចំនួន យកតាមប្រកាសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ខ- ហាមឃាត់ការប្រើប្រាស់ឧបករណ៍នេសាទមួយចំនួនមានដូចខាងក្រោម ៖

- ឈិបយន្ត
- អួនអូសគូរ ឬអួនហ៊ុមរូមផ្សំភ្លើង ដែលធ្វើឱ្យត្រី ឬវារីសត្វកុំ មងខ្ញូរ មងកេវ
- អួនស្បៃមុងគ្រប់ប្រភេទ
- ឧបករណ៍ឆក់ គ្រឿងផ្ទុះ និងសារធាតុពុលគ្រប់ប្រភេទ
- ការនេសាទដោយឧបករណ៍ឈ្នាងអូសក្រែងឈាម នៅតំបន់ឆ្នេរសមុទ្រដែលអូស ឬរុញដោយកម្លាំងម៉ាស៊ីន
- ឧបករណ៍ទំនើប ឬឧបករណ៍នេសាទដែលបង្កើតថ្មី ឬរបៀបនេសាទបែបថ្មី ដែលនាំមកនូវការបំផ្លាញមច្ឆជាតិ ធនធានជលផល ប្រព័ន្ធអេកូឡូស៊ីជលផល ឬដែលគ្មានកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខា ប្រមាញ់ និងនេសាទ
- ពុល ឬចាប់សត្វទឹកស្លាបគ្រប់ប្រភេទ
- ចាប់ ឬទិញកូនក្តាមថ្ម ក្តាមសេះ និងកូនត្រីតុក
- ហាមឃាត់ការប្រមូល ចាប់ក្តាមជំរ ដោយការជីក គាស់ កកាយរន្ធតាមវាលភក់ ព្រៃកោងកាង
- ហាមឃាត់ការផលិត ការទិញ ការលក់ ការដឹកជញ្ជូន ការរក្សាទុកឧបករណ៍ឆក់ ស្បៃមុងគ្រប់ប្រភេទ អួនអូសគូរ និងឈិបយន្តក្នុងបំណងធ្វើនេសាទ
- ការចាប់ ការលក់ ការទិញ ការធ្វើសន្និធិ និងការដឹកជញ្ជូនកូនត្រី និងពងត្រី ឬពងវារីសត្វផ្សេងៗទៀត
- ការកាប់ ឆ្ការ គាស់ រាន ឈូសឆាយ និងការដុត ឬហ៊ុំព័ទ្ធកាន់កាប់ព្រៃកោងកាង
- ការគាស់កកាយយកថ្ម ដីខ្សាច់ និងរ៉ែ ដែលមាននៅក្នុងដែននេសាទ
- ការទិញ ឬការលក់សំបកពពួកខ្យង ខ្ចៅតាំងលំអរដែលជាប្រភេទកម្រ
- ការកាប់បំផ្លាញផ្តួលរំលំដើមឈើ ព្រៃកោងកាង ឬគាស់រំលើងប្រមូលគល់ឈើព្រៃកោងកាង
- ការប្រមូល ដឹកជញ្ជូន និងការធ្វើសន្និធិឈើ អុស ធ្យូង ប្រភេទឈើព្រៃកោងកាងជាលក្ខណៈអាជីវកម្ម ឬ ពាណិជ្ជកម្ម
- ការធ្វើនេសាទ ឬការធ្វើអាជីវកម្មផ្សេងៗទៀត ដែលប៉ះពាល់ ឬរំខានដល់ការលូតលាស់នៃស្មៅសមុទ្រ ឬ ផ្កាថ្ម
- ការប្រមូល ការទិញ ការលក់ ការដឹកជញ្ជូន និងការធ្វើសន្និធិផ្កាថ្ម
- ការបំផ្លាញស្មៅសមុទ្រ ឬផ្កាថ្មដោយសកម្មភាពផ្សេងៗទៀត
- ការពង្រីកផ្ទៃដីស្រែ ចំការ ឬស្រែអំបិលក្នុងដែននេសាទ
- ចាក់ចោល ការបោះចោល ការបង្ហូរ ឬការបាចព្រោយនៅក្នុងដែននេសាទនូវកាកសំណល់រឹង ឬរាវ ឬសារធាតុពុល ឬការប្រព្រឹត្តសកម្មភាព ដែលធ្វើឱ្យពុលឬបង្កគ្រោះថ្នាក់ដល់វារីសត្វ និងរុក្ខជាតិ

**ប្រការ ៧.-**

សមាជិកសហគមន៍នេសាទដែល ៖

- ប្រព្រឹត្តផ្ទុយ ឬរារាំងមិនឱ្យសមាជិកដទៃអនុវត្តសិទ្ធិ និងកាតព្វកិច្ចដូចក្នុងប្រការ ៥ នៃលក្ខន្តិកៈ ត្រូវព្យួរ សមាជិកភាពដោយគណៈកម្មការសហគមន៍នេសាទ ឬបណ្តេញចេញពីសមាជិកភាពដោយមហាសន្និបាត

- មិនចូលរួមថែរក្សាការពារធនធានជលផល ឬមិនរាយការណ៍អំពី សកម្មភាពបទល្មើសជលផល ត្រូវព្រមាន ដោយគណៈកម្មការសហគមន៍នេសាទ

- ប្រើប្រាស់ឧបករណ៍ហាមឃាត់ ធ្វើនេសាទខុសច្បាប់ កាប់ឆ្ការរានព្រៃលិចទឹក ព្រៃកោងកាង ឬបំផ្លាញផ្កាថ្ម ឬស្មៅសមុទ្រ ត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ស្តីពី ជលផល

- ធ្វើនេសាទក្នុងតំបន់អភិរក្សរបស់សហគមន៍នេសាទ ត្រូវផ្អាកការនេសាទ ហើយធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ រាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលជលផលមានសមត្ថកិច្ច

- អនុវត្តផ្ទុយ នឹងបទប្បញ្ញត្តិច្បាប់ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀង ឬផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវផ្អាកការនេសាទ ទទួលការព្រមានជាលាយលក្ខណ៍អក្សរ ធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ជូនទៅរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីដោះស្រាយតាមច្បាប់។

**ប្រការ៨.-**

❖ ចំពោះអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទ ហើយរស់នៅក្នុងភូមិអាចមានសិទ្ធិចេញចូល និងនេសាទក្នុងកន្លែងនេសាទសហគមន៍ ប៉ុន្តែត្រូវជូនព័ត៌មានដល់គណៈកម្មការសហគមន៍នេសាទ ធ្វើកិច្ចសន្យា និង គោរពកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងត្រូវបង់ភាគទានចំនួន ២០.០០០រៀល (ពីរម៉ឺនរៀល) ក្នុងរយៈពេល ១០ ឆ្នាំ (មួយឆ្នាំ) បើលើសរកនេសាទរយៈពេល ពី១ឆ្នាំ (មួយឆ្នាំ) ត្រូវបង់ចំនួន ២០.០០០រៀល (ពីរម៉ឺនរៀល) ជាថ្មីម្តងទៀត សម្រាប់ជួយទ្រទ្រង់សហគមន៍នេសាទ ផ្អែកតាមស្ថានភាពជាក់ស្តែង ដែលអនុញ្ញាតិបានដោយគណៈកម្មការសហគមន៍នេសាទ ។

❖ ចំពោះអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទ ហើយរស់នៅក្រៅភូមិអាចមានសិទ្ធិចេញចូល និងនេសាទក្នុងកន្លែងនេសាទសហគមន៍ ប៉ុន្តែត្រូវជូនព័ត៌មានដល់គណៈកម្មការសហគមន៍នេសាទ ហើយធ្វើកិច្ចសន្យា និង គោរពកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងត្រូវបង់ភាគទានចំនួន ៥០.០០០រៀល (ប្រាំម៉ឺនរៀល) ក្នុងរយៈពេល ១០ថ្ងៃ (ដប់ថ្ងៃ) បើលើសរកនេសាទរយៈពេល ពី ១០ថ្ងៃ (ដប់ថ្ងៃ) ត្រូវបង់ចំនួន ៥០.០០០រៀល (ប្រាំម៉ឺនរៀល) ជាថ្មីម្តងទៀត សម្រាប់ជួយទ្រទ្រង់សហគមន៍នេសាទផ្អែកតាមស្ថានភាពជាក់ស្តែង ដែលអនុញ្ញាតិបានដោយគណៈកម្មការសហគមន៍នេសាទ ។

ក្នុងករណីដែលអ្នកប្រើប្រាស់ធនធានជលផល ដែលមិនមែនជាសមាជិកសហគមន៍នេសាទ មិនបានគោរពតាម ប្រការនេះ គណៈកម្មការសហគមន៍នេសាទមានសិទ្ធិបញ្ឈប់សកម្មភាពនេសាទរបស់គេ ហើយធ្វើការអប់រំណែនាំ។

**ប្រការ ៩.-**

បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទលើកដំបូងនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាដោយប្រធានគណៈកម្មការសហគមន៍នេសាទ។

ធ្វើនៅភូមិកែប ថ្ងៃទី.....១.... ខែ.....១...ឆ្នាំ២០១១

**ប្រធានគណៈកម្មការសហគមន៍នេសាទភូមិកែប**

# សេចក្តីថ្លែងការណ៍

យើងខ្ញុំគណៈកម្មការសហគមន៍នេសាទភូមិកែប ដែលបានបង្កើតនៅក្នុងឆ្នាំ ២០០៧ ក្រោមការឧបត្ថម្ភបច្ចេកទេសដោយរដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលជលផលកំពត ។

យើងខ្ញុំសូមគោរពជម្រាបជូនលោកនាយខណ្ឌរដ្ឋបាលជលផលជ្រាបថា ការផ្តួចផ្តើមបង្កើតសហគមន៍នេសាទនេះ បានកើតឡើងបន្ទាប់ពីមានភាពអណាធិបតេយ្យនៃការនេសាទខុសច្បាប់ និងទំនាស់ដែននេសាទធ្វើឲ្យប្រជាពលរដ្ឋភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប បានឯកភាពគ្នាធ្វើសំណើសុំបង្កើត សហគមន៍នេសាទភូមិកែបនេះឡើង និងស្របតាមគោលនយោបាយកំណែទំរង់វិស័យជលផល របស់រាជរដ្ឋាភិបាលនៅខែតុលា ឆ្នាំ ២០០០។ ក្នុងគោលបំណង ការពារ គ្រប់គ្រង ប្រើប្រាស់ អភិរក្ស អភិវឌ្ឍន៍ធនធានធម្មជាតិប្រកបដោយចីរភាព ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រក្នុងសហគមន៍មូលដ្ឋាន ។

ចាប់តាំងពីចាប់ផ្តើមបង្កើតសហគមន៍នេសាទក្នុងឆ្នាំ ២០..... រហូតមកដល់សព្វថ្ងៃ សហគមន៍នេសាទយើងខ្ញុំបានខិតខំប្រឹងប្រែងធ្វើការងារសំខាន់ៗជាច្រើនដូចជា មានដាក់ស្លាកសញ្ញាផ្សព្វផ្សាយពីសារៈសំខាន់នៃធនធានជលផលដើម្បីបង្កើនការចូលរួមពីប្រជាពលរដ្ឋក្នុងការគ្រប់គ្រងធនធានជលផល ការបង្កើតគណៈកម្មការសហគមន៍នេសាទ ការងារយាមល្បាតបង្ក្រាបបទល្មើស រាយការណ៍ពីសកម្មភាពផ្សេងៗទៅស្ថាប័នជំនាញ និងក្រុមប្រឹក្សាឃុំ បណ្តុះបណ្តាលការសរសេរសំណើសាមញ្ញខ្លីៗ សរសេររបាយការណ៍ និងសរសេរកំណត់ហេតុជំនាញសម្របសម្រួល រៀបចំបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍ផែនទីកន្លែងនេសាទសហគមន៍ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ សេចក្តីថ្លែងការណ៍ និងការអភិវឌ្ឍន៍សហគមន៍នេសាទ ។ល។ ទន្ទឹមនឹងនេះ សហគមន៍នេសាទយើងខ្ញុំបានរៀបចំរួចរាល់នូវឯកសារសម្រាប់បង្កើតសហគមន៍នេសាទដូចមានចែងក្នុងមាត្រា ៧ ជំពូកទី ២ នៃអនុក្រឹត្យស្តីពី ការគ្រប់គ្រងសហគមននេសាទ ដែលរួមមានបញ្ជីឈ្មោះសមាជិកសហគមន៍ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង និងផែនទីកន្លែងនេសាទសហគមន៍ ។

ដោយផ្អែកលើសមិទ្ធិផលដូចបានរៀបរាប់ខាងលើ និងការសម្រេចរបស់មហាសន្និបាត ដែលបានប្រារព្ធធ្វើនៅថ្ងៃទី..........ខែ.............ឆ្នាំ២០..... យើងខ្ញុំគណៈកម្មការតំណាងឲ្យសហគមន៍នេសាទភូមិកែប សូមគោរពជូនលោកនាយខណ្ឌរដ្ឋបាលជលផល នូវកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ដែលមានភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ និងផែនទីកន្លែងនេសាទសហគមន៍ ដើម្បីពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ ។

យើងខ្ញុំ គណៈកម្មការសហគមន៍នេសាទភូមិកែប សូមធ្វើការប្តេជ្ញាចិត្ត និងសន្យាថានឹងដឹកនាំក្នុងការគ្រប់គ្រងសហគមន៍នេសាទ ដោយគោរពទៅតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ និងច្បាប់លិខិតបទដ្ឋាននានា ដែលទាក់ទងនឹងវិស័យជលផល ។

បើសិន ជាយើងខ្ញុំ បានប្រព្រឹត្តអ្វីខុសនឹងកិច្ចព្រមព្រៀងខាងលើ យើងខ្ញុំសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ជាធរមាន ។

អាស្រ័យហេតុនេះ សូមលោកនាយខណ្ឌរដ្ឋបាលជលផល មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

ធ្វើនៅភូមិកែប ថ្ងៃទី....៧....ខែ.....៤......ឆ្នាំ ២០១១

**ប្រធានគណៈកម្មការសហគមន៍នេសាទភូមិកែប**

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាពិនិត្យ និងសម្រេចដោយអនុគ្រោះ ។

ធ្វើនៅភូមិកែប ថ្ងៃទី.....១.... ខែ.....១...... ឆ្នាំ ២០១១

**ប្រធានគណៈកម្មការសហគមន៍នេសាទភូមិកែប**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១៤០ ប្រក កសក

# ប្រកាស

## ស្តីពី

## ការចុះបញ្ជីសហគមន៍នេសាទចំនួន៣២ នៅខេត្តរតនគិរី មណ្ឌលគិរី កែប ព្រៃវែង និងខេត្តក្រចេះ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្មនិងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ
- បានឃើញប្រកាសលេខ៦៨១ ប្រក.កសក.ប ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់របស់ការិយាល័យនិងមន្ទីរពិសោធន៍ចំណុះនាយកដ្ឋាននិងវិទ្យាស្ថានក្រោមឱវាទរដ្ឋបាលជលផល
- បានឃើញប្រកាសលេខ៣១៦ ប្រក.កសក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

# សម្រេច

**ប្រការ ១.-**

ត្រូវបានចុះបញ្ជីជាផ្លូវការនិងទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នូវសហគមន៍នេសាទ ចំនួន៣២ រួមមាន៖ ខេត្តរតនគិរីចំនួន០៦សហគមន៍ ខេត្តមណ្ឌលគិរីចំនួន០១សហគមន៍ ខេត្តកែបចំនួន០៥សហគមន៍ ខេត្តព្រៃវែងចំនួន០៤សហគមន៍ និងខេត្តក្រចេះចំនួន១៦សហគមន៍ ដែលមានឈ្មោះសហគមន៍នេសាទ ចំនួនសមាជិក ចំនួនគណៈកម្មការ ទំហំកន្លែងនេសាទសហគមន៍ ឈ្មោះភូមិ ឃុំ ស្រុក ខេត្ត និងនិយាមកាជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍ ដូចមាននៅក្នុងតារាងនិងផែនទីកន្លែងនេសាទសហគមន៍នីមួយៗជាឧបសម្ព័ន្ធភ្ជាប់ប្រកាសនេះ។

**ប្រការ ២.-**

ព្រំប្រទល់កន្លែងនេសាទសហគមន៍នីមួយៗដែលបានកំណត់ក្នុងផែនទី ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវបានទទួលស្គាល់ដោយនាយខណ្ឌរដ្ឋបាលជលផល អាជ្ញាធរដែនដី ប្រធានរដ្ឋបាលជលផល និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ប្រការ ៣.-**

ទំហំកន្លែងនេសាទសហគមន៍ និយាមកាជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍ ចំនួនភូមិ និងទីតាំងភូមិសាស្ត្ររបស់សហគមន៍ដូចមានចែងក្នុងប្រការ១ អាចកែប្រែបានតាមការចាំបាច់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ៤.-**

ប្រកាសឬសេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលជលផល អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្មខេត្តពាក់ព័ន្ធ និងប្រធានគណៈកម្មការសហគមន៍នេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ ០៨ ឆ្នាំ២០១៣

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេច អគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- សាលាខេត្តពាក់ព័ន្ធ
- ដូចប្រការ ៥
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធ:** ភ្ជាប់ប្រកាសលេខ......១៤០......ប្រ.កសក.ចុះថ្ងៃទី..០៧......ខែ..វិច្ឆិកា.........ឆ្នាំ២០១៣

# សហគមន៍នេសាទក្នុងខេត្តរតនគិរី មណ្ឌលគិរី កែប ព្រៃវែង និងខេត្តក្រចេះ

| ល.រ | ឈ្មោះសហគមន៍នេសាទ | ចំនួនសមាជិក | ចំនួនសមាជិកគណៈកម្មការសហគមន៍ | ទំហំផ្ទៃសហគមន៍ (ហិកតា) | ភូមិ | ឃុំ/សង្កាត់ | ស្រុក/ក្រុង | Projection : UTM, Everest 1830, Datum : Indian 1960, Zone : 48 N, Unit: Meter (X,Y) | (X,Y) |
|---|---|---|---|---|---|---|---|---|---|
| **១-ខេត្តរតនគិរី** | | | | | | | | | |
| ១ | កែងសាន់ | ១៦១ | ០៥ | ២៨២,៨៧ | កែងសាន់ | សេដា | លំផាត់ | A. (724301, 1476995)<br>B. (730544, 1472794)<br>C. (741395, 1474736) | D. (734332, 1473453)<br>E. (725997, 1472835)<br>F. (737803, 1471920) |
| ២ | ជ័យឧត្តមលើ | ៤០៤ | ០៥ | ៧៣០ | ថ្មី លំផាត់ ដីឡូត៍ | ជ័យឧត្តម | លំផាត់ | A. (722850, 1470131)<br>B. (724299, 1476988)<br>C. (712326, 1493808) | D. (721569, 1478751)<br>E. (716496, 1489522)<br>F. (724586, 1475449) |
| ៣ | ហាត់ប៉ក់ | ១៣៩ | ៥ | ៥០០ | វឺនហយ ហាត់ប៉ក់ ឡាំប៉ាត់ | ហាត់ប៉ក់ | វើនសៃ | A. (684656, 1530496)<br>B. (680907, 1529095)<br>C. (681919, 1532623) | D. (688126, 1531778)<br>E. (681881, 1531999)<br>F. (684289, 1531232) |
| ៤ | តាវែងលើ | ២២២ | ០៧ | ៥៣៣ | ភ្លឺធំ រៀងវិញ ប៉ាគិត កិគ្នង សញ | តាវែងលើ | តាវែង | A. (728008, 1553966)<br>B. (738099, 1552188)<br>C. (735239, 1556016) | D. (728640, 1555376)<br>E. (729554, 1556024)<br>F. (735194, 1556454) |
| ៥ | កែងសកាងតាឡាវ | ៤៩៦ | ០៩ | ៦៣០ | តាឡាវ កាក់ កាណាត អ៊ីន តាណង | តាឡាវ | អណ្ដូងមាស | A. (741802,1541984 )<br>B. (748514, 1535048)<br>C. (739546, 1545570) | D. (741021, 1550755)<br>E. (744107, 1540697)<br>F. (741156, 1552703) |
| ៦ | តាំងគូមបរខាំ | ១២៨ | ០៩ | ៣៩៤,៣៥ | តាំងសេ ដាល កាជូត លោម | ញ៉ាង ម៉ាលិក | អណ្ដូងមាស | A. (752467, 1535392)<br>B. (756032, 1527886)<br>C. (748514, 1535[illegible]) | D. (750035, 1533973)<br>E. (755792, 1530197)<br>F. (755948, 1530275) |
| **២-ខេត្តមណ្ឌលគិរី** | | | | | | | | | |
| ១ | អូរច្បារ | ៣១៥ | ០៧ | ១៦៨,២៩ | ស្រែជ្រៃ | ណងឃីលឹក | កោះញែក | A. (722685, 1455351)<br>B. (725118, 1459082)<br>C. (728000, 1461454) | D. (727449, 1469165)<br>E. (726176, 1463[illegible])<br>F. (726842, 1[illegible]) |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| **៣-ខេត្តកែប** | | | | | | | | | |
| ១ | អង្កោល | ២០០ | ០៩ | ១៦៩៥ | អង្កោល | អង្កោល | ដំណាក់ចង្អើរ | A. (429248, 1155003)<br>B. (433793, 1157803)<br>C. (432934, 1155687) | D. (436907, 1155203)<br>E. (436481, 1154019)<br>F. (433996, 1152205) |
| ២ | កែប | ១១១ | ០៩ | ២៧០ | កែប | ព្រៃធំ | កែប | A. (426189, 1158632)<br>B. (426810, 1159083)<br>C. (428424, 1159992) | D. (428720, 1158929)<br>E. (426433, 1157653) |
| ៣ | ភូមិថ្មី | ១០៣ | ០៧ | ១៩៨ | ភូមិថ្មី | ព្រៃធំ | កែប | A. (420233, 1161977)<br>B. (420664, 1161090)<br>C. (422463, 1161899) | D. (422359, 1162196)<br>E. (422311, 1162273)<br>F. (422114, 1162812) |
| ៤ | កំពង់ត្រឡាច | ១១៦ | ០៥ | ៤២២ | កំពង់ត្រឡាច | ព្រៃធំ | កែប | A. (419596, 1163393)<br>B. (421359, 1164848)<br>C. (421920, 1163920) | D. (422103, 1163640)<br>E. (422115, 1163098)<br>F. (422114, 1162812) |
| ៥ | អូរក្រសារ | ២៣៦ | ១១ | ៤៤៦ | អូរក្រសារ | អូរក្រសារ | កែប | A. (418364, 1164788)<br>B. (420111, 1165772)<br>C. (420173, 1166180) | D. (420392, 1165811)<br>E. (421359, 1164848)<br>F. (419596, 1163393) |
| **៤-ខេត្តព្រៃវែង** | | | | | | | | | |
| ១ | ដំរីពួន | ២១៨៩ | ០៩ | ១៥៨,៤១ | ព្រៃភ្លាំង តាំប្រជីស ចំការគួយលិច ដំរីពួន ត្បូងក្តី អូរកណ្តោលត្បូង | ដំរីពួន | ស្វាយអន្ទរ | A. (542037, 1268243)<br>B. (543822, 1267524)<br>C. (542372, 1267753) | D. (545288, 1270022)<br>E. (545111, 1270784)<br>F. (542954, 1269129) |
| ២ | ថ្មីសម័យតេជោ | ៦៣៤០ | ០៧ | ៧២៦,៦ | តាគាត់ សំរោង ព្រៃឈើទាល ព្រៃឃ្នង ភូមិថ្មី ព្រហ៊ុត ត្រាច ព្រលឹងមាស កណ្តាល | សំរោង | ស្វាយអន្ទរ | A. (522750, 1267524)<br>B. (543832, 1264413)<br>C. (546206, 1260095) | D. (546134, 1260019)<br>E. (543169, 1261942)<br>F. (543200, 1262876) |
| ៣ | បឹងស្នេហ៍ធាយ | ៤៦១៦ | ០៥ | ៦១៤,៧៤ | ធាយ កំពង់ស្នេហ៍ កំពង់ស្លែង ទំពស្តេច តាសូ | ធាយ | បាភ្នំ | A. (543616, 1258788)<br>B. (543656, 1261067)<br>C. (546126, 1259925) | D. (543965, 1261609)<br>E. (543176, 1261944)<br>F. (542312, 1257642) |
| ៤ | មហាជ័យជំនះ | ៥១១៨ | ០៧ | ៦៥៥ | ព្រៃខ្លា ព្រៃអង្គុញ បារាយណ៍កើត | ព្រៃកណ្តៀង បារាយណ៍ | ពាមរក៍ ព្រៃវែង | A. (541996, 1268290)<br>B. (543305, 1263657)<br>C. (543190, 1262865) | D. (542312, [illegible])<br>E. (542471, 12653[illegible])<br>F. (541[illegible]37, 12682[illegible]) |

៥-ខេត្តក្រចេះ

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១ | កោះស័ក្តសិទ្ធិ | ១១៤ | ០៩ | ៣២៩ | កោះវ្គាំ | កំពង់ចាម | សំបូរ | A. (602749, 1420944)<br>B. (601565, 1420965)<br>C. (601908, 1420264) | D. (602101, 1417504)<br>E. (603050, 1417724)<br>F. (602836, 1418867) |
| ២ | អន្លង់វាលព្រលូង លូងចិត្ត | ១១៤ | ០៩ | ៥៧២ | អំពិលទឹក | កំពង់ចាម | សំបូរ | A. (604188, 1423964)<br>B. (605637, 1426284)<br>C. (608138, 1430714) | D. (608553, 1431801)<br>E. (608728, 1433468)<br>F. (604142, 1424776) |
| ៣ | អន្លង់កំណាប់ | ១០០ | ០៩ | ៣៧២ | កោះច្បារ | កោះខ្ញែរ | សំបូរ | A. (608780, 1424579)<br>B. (608123, 1424502)<br>C. (609064, 1426646) | D. (609559, 1427687)<br>E. (609935, 1428936)<br>F. (610573, 1430252) |
| ៤ | តាកិះខ្លាស្នុះ | ១១៩ | ០៩ | ៤៦០,៥ | កំពង់ព្នៅ | កោះខ្ញែរ | សំបូរ | A. (612918, 1432543)<br>B. (613754, 1433436)<br>C. (614634, 1434617) | D. (612818, 1433720)<br>E. (610996, 1431321)<br>F. (611174, 1429808) |
| ៥ | តាងួន | ២៥៧ | ០៩ | ៤៧៨ | តាងួន | វឌ្ឍនៈ | សំបូរ | A. (606742, 1404132)<br>B. (607276, 1407286)<br>C. (607290, 1406833) | D. (605459, 1406268)<br>E. (606209, 1405070)<br>F. (606501, 1404478) |
| ៦ | ព្រែកព្រលូង | ៣២៦ | ០៩ | ៥០៩ | ព្រែកព្រលូង | សោប | ព្រែកប្រសព្វ | A. (610692, 1376740)<br>B. (609499, 1375874)<br>C. (609059, 1374879) | D. (609550, 1373758)<br>E. (610081, 1373551)<br>F. (611690, 1374993) |
| ៧ | ព្រែកប្រាំង | ៤៥៤ | ០៩ | ៣៦៥ | ព្រែកប្រាំង | ព្រែកប្រសព្វ | ព្រែកប្រសព្វ | A. (611831, 1367509)<br>B. (610326, 1369257)<br>C. (608843, 1368570) | D. (609792, 1370651)<br>E. (611127, 1371098)<br>F. (610897, 1369478) |
| ៨ | ស្វាយជ្រុំ | ៩៥ | ០៩ | ១១១ | ស្វាយជ្រុំ | ថ្មី | ចិត្របុរី | A. (638156, 1382161)<br>B. (638602, 1382299)<br>C. (638358, 1382913) | D. (637886, 1383384)<br>E. (637447, 1383207)<br>F. (637397, 1382809) |
| ៩ | ដូនត្រី | ៣៦៣ | ០៩ | ១១ | ចំណោលនិងខ្នាច | ថ្មី | ចិត្របុរី | A. (634753, 1382687)<br>B. (634806, 1382804)<br>C. (634634, 1382872) | D. (634476, 1382915)<br>E. (634340, 1382889)<br>F. (634290, 1382802) |
| ១០ | ផ្សៀរ | ៣២៦ | ០៧ | ៦៥ | ផ្សៀរ | ថ្មី | ចិត្របុរី | A. (648279, 1380863)<br>B. (648366, 1380875) | C. (648513, 1377336)<br>D. (648413, 1377327) |
| ១១ | ទំនប់អូរកន្ទួត | ៨២ | ០៩ | ១៥ | កន្ទួត | កន្ទួត | ចិត្របុរី | A. (628127, 1379289)<br>B. (628216, 1379413)<br>C. (628200, 1379746) | D. (628087, 1379848)<br>E. (627897, 1379589)<br>F. (627801, 1379532) |
| ១២ | បឹងម្លិច | ៨៤ | ០៩ | ១២ | អន្លង់វៀន | កន្ទួត | ចិត្របុរី | A. (630103, 1377558)<br>B. (629952, 1377489)<br>C. (629826, 1377420) | D. (629766, 1377499)<br>E. (629956, 1377577)<br>F. (629991, 1377503) |
| ១៣ | បឹងកាស់ | ៩៣ | ១១ | ៦៨ | ម្រើម | ជារ | ចិត្របុរី | A. (617213, 1377961)<br>B. (617684, 1377925)<br>C. (617848, 1377451) | D. (617989, 1377670)<br>E. (617798, 1377069)<br>F. (616929, [illegible]) |
| ១៤ | បឹងរុន | ៧០ | ០៩ | ៣៩,៥ | បឹងរុន | សំបុក | ចិត្របុរី | A. (614221, 1397281)<br>B. (615768, 1395142) | C. (6136[illegible], [illegible]374767)<br>D. (61[illegible]798, 139[illegible]) |
| ១៥ | សំបុក | ៤០៥ | ១១ | ២៩១ | សំបុក | សំបុក | ចិត្របុរី | A. (611459, 1389471)<br>B. (612647, 1391037)<br>C. (612808, 1391982) | D. (612923, [illegible])<br>E. (6[illegible]755, 139[illegible])<br>F. (6[illegible]1910, 1391[illegible]) |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១៦ | ស្រែថ្មី | ២២៤ | ១១ | ៩៤ | ស្រែថ្មី | ឃ្សឹម | ស្នួល | A. (667773, 1346561)<br>B. (663077, 1349413)<br>C. (663501, 1351224) | D. (663436, 1351225)<br>E. (663005, 1349342)<br>F. (667746, 1346512) |

បានឃើញនិងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៣

ជ. រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

រដ្ឋលេខាធិការ

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

[illegible]

ណៅ_ឆ្នុក